

# កំណែទំរង់គោលនយោបាយវិស័យជលផល
# និងទស្សនៈថ្មីៗស្តីពីសហគមន៍នេសាទ
# និងសហគ្រប់គ្រងនេសាទ

ករណីសិក្សា

នៅតំបន់ឡូត៍នេសាទ

ខេត្តសៀមរាប និងខេត្តបាត់ដំបង

ព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវ និងចងក្រងដោយ :

លោក ម៉ាយ សុគុមី

២០០២

# កំណែទំរង់គោលនយោបាយវិស័យជលផល និងទស្សនៈថ្មីៗស្តីពី
# សហគមន៍នេសាទ និងសហគ្រប់គ្រងនេសាទ

**ករណីសិក្សា**

នៅឡូតិ៍នេសាទលេខ ៣, លេខ ៦ លេខ ៣ , ៥ ខេត្តសៀមរាប និងបាត់ដំបង

នៃព្រះរាជាណាចក្រកម្ពុជា

**ស្រាវជ្រាវ និងចងក្រងដោយ :**

លោក ថាយ សុមុនី

**២០០២**

ធនធានជលផលទឹកសាប មានសារៈសំខាន់ណាស់សំរាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា។ គោលបំណងនៃការកែទំរង់វិស័យជលផល ដើម្បីកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជននៅតាមជនបទ ព្រមទាំងផ្តល់សិទ្ធិក្នុងការធ្វើនេសាទដល់សហគមន៍មូលដ្ឋាន និងអាចជៀសវាងបាននូវការជះឥទ្ធិពលជាអវិជ្ជមានដល់ប្រពន្ធ័ចិញ្ចឹមជីវិត។ ការរៀបចំសហគមន៍នេសាទ និងសហគ្រប់គ្រង គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិដល់ការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព ព្រមទាំងអាចទទួលផលប្រយោជន៍បានសមស្រប។ នេះជាទស្សនៈថ្មីចំពោះបរិបទនយោបាយនៅកម្ពុជា ហើយវានៅមានកង្វះខាត ចំណេះដឹងខ្លះ ព្រមទាំងពុំទាន់បានអនុវត្តទាំងស្រុងនូវរបៀបនេះតាមតំបន់មួយចំនួនទៀត។ ប្រជាជនខ្លះមានការយល់ដឹងពីសហគ្រប់គ្រងនេសាទ ដែលមានសារៈប្រយោជន៍ដល់ជីវភាពរស់នៅ ហើយពួកគាត់មានជំនឿថា បច្ចុប្បន្នពួកគាត់ធ្វើនេសាទតាមរបៀបសហគមន៍នេសាទដោយមានលក្ខន្តិកៈកំណត់យ៉ាងច្បាស់លាស់។ រីឯប្រជាជនមួយចំនួនមានការយល់ថា កំណែទំរង់វិស័យជលផលនេះ នឹងអនុញ្ញាតិអោយមានតែការនេសាទលក្ខណៈគ្រួសារប៉ុណ្ណោះ។ ទស្សនៈទាំងនេះជាកត្តាចំបង ដើម្បីវិភាគបាននូវការអនុវត្តរបៀបសហគ្រប់គ្រងនេសាទ ដែលជាយុទ្ធសាស្រ្តជោគជ័យថ្មីមួយនៃកំណែទំរង់វិស័យជលផលបច្ចុប្បន្ន។

ករណីសិក្សានេះ ត្រូវបានធ្វើឡើងជាចំបងតាមរយៈការសំភាសន៍ជាមួយប្រជានេសាទនៅក្នុងតំបន់ឡូតិ៍លេខ ៣ លេខ ៦ ក្នុងខេត្តសៀមរាប និងឡូតិ៍លេខ ៣ លេខ ៥ ក្នុងខេត្តបាត់ដំបង ហើយព្រមទាំងបានពិគ្រោះយោបល់ខ្លះៗ ជាមួយមន្រ្តីរាជការជលផលខេត្ត បុគ្គលិកគំរោង FAO ខេត្តសៀមរាប និងបុគ្គលិកគំរោង LEUCAENA ផងដែរ។

IDRC CRDI CANADA

Oxfam America

WWF

**ស្រាវជ្រាវ និងចងក្រងដោយ :**

**លោក ម៉ាយ សុមុនី**

មន្ត្រីរាជការនាយកដ្ឋានជលផល

កម្មវិធីអនុបណ្ឌិតផ្នែកគ្រប់គ្រង ស្តីពីធនធានអាហារ និងគ្រប់គ្រងពាណិជ្ជសាស្ត្រកសិកម្ម

វិទ្យាល័យភូមិន្ទកសិកម្ម ប្រទេសអង់គ្លេស

ប្រធានស្តីទី ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃនាយកដ្ឋានជលផល

**អ្នកចូលរួមសំខាន់**

**លោក សៅ ឡូក**

ប្រធាននាយកដ្ឋានជលផល

ក្រុមគំរោងករណីសិក្សា " ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម"

លោក ប៉ាទ្រីក អែវ៉ាន និងបុគ្គលិកអង្គការហ្វាវ ខេត្តសៀមរាប

សមាជិកសហគមន៍នេឡូត៍នេសាទលេខ ៣ . លេខ ៦ និងលេខ ៣. ៥ ខេត្តសៀមរាប និងបាត់ដំបង

បុគ្គលិកគំរោង លូស៊ីណា នៃខេត្តបាត់ដំបង

លោក និកូឡា វ៉ាន់ស្សាលីន ទីប្រឹក្សាបច្ចេកទេស គ្រោងការគ្រប់គ្រងនេសាទទឹកសាបកម្ពុជា

**ទីប្រឹក្សា**

**លោក ឌូចី ឌាញ៉ែន**

ទីប្រឹក្សាគំរោងករណីសិក្សា " ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម"

**កែសំរួលដោយ:**

**លោក កែវចិន វិចិ**

**ឧបត្ថម្ភដោយ**

-ការចូលរួមគ្រប់គ្រងធនធានធម្មជាតិនៅក្នុងតំបន់បឹងទន្លេសាបរបស់អង្គការហ្វាវ ខេត្តសៀមរាប (FAO)

-គំរោងករណីសិក្សា " ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម" នៃអង្គការ WWF

-មជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិសំរាប់ការអភិវឌ្ឍន៍ (IDRC)

-អង្គការអុកស្វាមអាមេរិកាំង

-មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើថ្នាក់តំបន់ (RECOFTC)

# អារម្ភកថា

## ដំណើរការករណីសិក្សា

ដោយទទួលស្គាល់ថា ការគ្រប់គ្រងធនធានដោយសហគមន៍ (CBNRM) គឺជាទស្សនៈ និងការអនុវត្តន៍ថ្មីមួយចំពោះប្រទេសកម្ពុជា ការចងក្រងឯកសារអំពីបទពិសោធន៍មូលដ្ឋាន និងមេរៀនដែលទទួលនេះ បង្កើតចេញជាសមាសភាគសំខាន់មួយនៃការវិភាគ និងការចែករំលែកពត៌មានរវាងសហគមន៍មូលដ្ឋាន គំរោង និងភ្នាក់ងារពាក់ព័ន្ធផ្សេងៗ ដែលធ្វើការទាក់ទង CBNRM នេះ។

ការចងក្រងករណីសិក្សានេះ គឺជាផ្នែកមួយនៃគំនិតផ្តួចផ្តើមរៀនសូត្រចម្រុះមួយ (ដោយផ្អែកលើគំរូវដ្តរៀនសូត្រដែលជាបទពិសោធន៍មួយ) ដែលមានរយៈពេលចាប់ពីខែ មិថុនា ឆ្នាំ ២០០១ ដល់ ខែវិច្ឆិកា ឆ្នាំ ២០០២ និងអាចមានរយៈពេលយូរជាងនេះទៅទៀត ។ ការបណ្តុះបណ្តាលដំបូងអំពីការសរសេរករណីសិក្សាដែលបានធ្វើឡើងនៅខេត្តសៀមរាបសំរាប់អ្នកអនុវត្តគំរោង CBNRM ជាង ៣០ នាក់ នៅខែកក្កដា ឆ្នាំ ២០០១ ដើម្បីផ្តល់ជំនាញ គ្រឹះសំរាប់ការសិក្សាស្រាវជ្រាវ PRA ការវិភាគពត៌មាន ការសរសេរអត្ថបទ និងចងក្រងឯកសារ។ ជាលទ្ធផល នៃតម្រូវការខ្ពស់សំរាប់ការងារប្រភេទនេះ វគ្គបណ្តុះបណ្តាលករណីសិក្សាមួយទៀតបានធ្វើឡើងនៅ ខែ វិច្ឆិកា ឆ្នាំ ២០០១ នៅខេត្តរតនៈគិរី ដែលមានអ្នកចូលរួមជាង ៤០ នាក់ ដើម្បីបង្កើនជំនាញខាងការស្រាវជ្រាវ និងជំនាញសរសេរអត្ថបទ ដើម្បីផ្តួចផ្តើមបង្កើតជាក្របខ័ណ្ឌការងារដែលជាទស្សនទានមួយសំរាប់ការងារ CBNRM នៅក្នុងប្រទេសកម្ពុជា។ ជាលទ្ធផលបានមកពីការបណ្តុះបណ្តាលនេះ យើងបានរៀបចំផែនការការងារករណីសិក្សាមួយដែលមានបញ្ចូលទាំងការកំណត់ប្រធានបទ និងសេចក្តីព្រាងគំនិត។

ករណីសិក្សានេះ គឺជាផ្នែកមួយនៃករណីសិក្សាចំនួន ១០ ធ្វើការផ្តោតទៅលើទាំងបញ្ហាជលផល និងបញ្ហាព្រៃឈើដែលបានបង្កើតឡើងនៅក្នុងភូមិសាស្ត្រសំខាន់ ៤ នៃប្រទេសកម្ពុជាដែលមាន តំបន់ខ្ពង់រាប (ខេត្តរតនៈគិរី និងមណ្ឌលគិរី) តំបន់ទំនាបកណ្តាល (ខេត្តពោធិសាត់ និងកំពង់ឆ្នាំង) តំបន់ទន្លេមេគង្គ ឬទន្លេសាប (ខេត្តស្ទឹងត្រែង និងសៀមរាប) និងតំបន់ឆ្នេរ (ខេត្តកោះកុង និងក្រុងកំពង់សោម)។

តាមករណីជាច្រើន សេចក្តីព្រាងលើកទី ១ របស់ករណីសិក្សាទាំង១០ ត្រូវបានបង្កើតឡើងដោយក្រុមស្រាវជ្រាវ និងអ្នកនិពន្ធ ចម្រុះដោយចាប់ពី ខែ មករា ដល់ ខែ មេសា ឆ្នាំ ២០០២ ។ សេចក្តីព្រាងលើកទី ២ ត្រូវបានលើយកមកបង្ហាញដើម្បីទទួលយកនូវការផ្តល់យោបល់ក្នុងពេលធ្វើសិក្ខាសាលា និងសិក្ខាសាលាបូកសរុបដែលបានធ្វើនៅខេត្តកោះកុង ខែ ឧសភា ឆ្នាំ២០០២។ នៅពេលនោះ ករណីសិក្សាទាំងនេះត្រូវបានពិនិត្យមើលបកប្រែជាភាសាអង់គ្លេស ហើយបានធ្វើការកែសម្រួលដើម្បីបោះពុម្ព និងផ្សព្វផ្សាយ។ អ្នកសម្របសម្រួលគំរោងនៅតាមមូលដ្ឋាន ដើរតួនាទីឈានមុខក្នុងការជ្រើសរើសប្រធានបទសម្រាប់ការសិក្សាស្រាជ្រាវ ការប្រមូលពត៌មាន និងការសរសេរអត្ថបទ។ អ្នកសម្របសម្រួល និងទីប្រឹក្សាថ្នាក់ជាតិផ្តល់ជាជំនួយលើការពិនិត្យមើលគំរោងករណីសិក្សា ការវិភាគពត៌មាន ការបកប្រែ និងការកែសម្រួល។

ដោយធ្វើការតាមគំនិតផ្តួចផ្តើមនេះ បានផ្តល់ឱ្យអ្នកចូលរួមក្នុងកម្រិតផ្សេងៗគ្នានូវឱកាសរៀនជំនាញបានកាន់តែច្រើន

ដើម្បីចែករំលែកបទពិសោធន៍ជាមួយគំរោង និងមនុស្សផ្សេងៗ ដែលធ្វើការខាងការងារ CBNRM នៅទូទាំងប្រទេសកម្ពុជា ។ តាមមធ្យោបាយបែបនេះ គំនិតផ្តួចផ្តើមចងក្រងករណីសិក្សា CBNRM ត្រូវបានគេប្រើជាឧបករណ៍មួយសម្រាប់បង្កើតជាបណ្តាញការងារ និងចែករំលែកមេរៀនដែលទទួលបាន។ ករណីសិក្សាទាំងនេះនឹងត្រូវបានគេចែករំលែកផងដែរ នៅតាមវេទិកានានាដូចជា សិក្ខាសាលាថ្នាក់ជាតិស្តីពី CBNRM ដែលនឹងធ្វើនៅខែ វិច្ឆិកា ឆ្នាំ ២០០២។ គេរំពឹងទុកថាលទ្ធផលនេះនឹងត្រូវ បានប្រើប្រាស់ ដើម្បីជាពត៌មានដល់ការបង្កើតគោលនយោបាយទៅថ្ងៃមុខនៅក្នុងប្រទេសកម្ពុជា។

## មាតិកាអត្ថបទ

### ធ្វើឲ្យអនុវត្តសហគ្រប់គ្រងនេសាទតាមរយៈកំណែទម្រង់គោលនយោបាយវិស័យជលផល

### ការវិភាគទស្សនៈរបស់សហគមន៍មូលដ្ឋាន  គឺជាយុទ្ធសាស្ត្រមួយដ៏មានសារៈសំខាន់


១.សេចក្តីផ្តើម ........................................ ៧

២.បញ្ហាសំខាន់ៗ ដែលបណ្តាលឱ្យមានការកែទម្រង់ការគ្រប់គ្រងជលផលទឹកសាប ........................................ ៨

៣.ទស្សនៈរបស់ប្រជានេសាទចំពោះការកែទម្រង់ការគ្រប់គ្រងវិស័យជលផល និងសហគ្រប់គ្រងនៃវិស័យជលផល ........ ១០

៤.សហគ្រប់គ្រងនៃធនធានជលផល ........................................ ១១

តារាងទី១: ភាពខុសគ្នារវាងសហគ្រប់គ្រង និងការគ្រប់គ្រងធនធានផ្អែកលើសហគមន៍ ........................................ ១៣

៥.ការភ័ន្តច្រឡំរវាងក្រុមសាមគ្គីនេសាទ រឺក្រុមសហករ និងសហគ្រប់គ្រងសហគមន៍នេសាទ ........................................ ១៤

៦.ការផ្សព្វផ្សាយពត៌មានមិនច្បាស់លាស់នៃសហគ្រប់គ្រង តាមរយៈបណ្តាញការផ្សព្វផ្សាយ ........................................ ១៥

៧.កំរិតយល់ដឹងរបស់សហគមន៍ក្នុងតំបន់ ........................................ ១៥

៨.ច្បាប់ជលផលចាស់ដែលហួសសម័យ ........................................ ១៦

៩.ការជំពាក់ទាក់ទិនទៅនឹងការបំផ្លាស់ប្តូរសង្គមនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ........................................ ១៧

១០.សេចក្តីសន្និដ្ឋាន ........................................ ១៨

១១.អនុសាសន៍ ........................................ ១៨

ឯកសារយោង: ........................................ ១៩

ប្រវត្តិគំរោងករណីសិក្សា "ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម" ........................................ ២៣

តារាងឧបសម្ព័ន្ធទី ១ ផលនេសាទចាប់បានប្រចាំឆ្នាំនៅកម្ពុជាពីឆ្នាំ ១៩៩៤ ដល់ ១៩៩៧

តារាងឧបសម្ព័ន្ធទី ២: ផែនទីបង្ហាញពីទីតាំងសិក្សា នៅឡូត៍លេខ ៣ និង ៦ ខេត្តសៀមរាប

តារាងឧបសម្ព័ន្ធទី ៣: ផែនទីបង្ហាញពីតំបន់ធ្វើករណីសិក្សានៅឡូលេខ៩ ខេត្តបាត់ដំបង

តារាងឧបសម្ព័ន្ធទី ៤: តំបន់ឡូត៍នេសាទក្រោយពេលកែទម្រង់វិស័យជលផល

## ដើម្បីអនុវត្តសហគ្រប់គ្រងនេសាទតាមរយៈគំណែនាំទៅគោលនយោបាយទិសដៅផលផល ការទិតាគនស្សេនៈរបស់សហគមន៍មូលដ្ឋាន គឺជាយុទ្ធសាស្ត្រមួយដ៏មានសារៈសំខាន់

### ១.សេចក្តីផ្តើម

កម្ពុជាជាប្រទេសមួយដែលសំបូរដោយធនធានធម្មជាតិ។ ក្នុងចំណោមធនធានទាំងនោះ ត្រីទឹកសាបជាធនធានសំខាន់មួយដែលផ្តល់នូវសុវត្ថិភាពស្បៀងអាហារ និងប្រាក់ចំណូលសំរាប់ប្រជាពលរដ្ឋកម្ពុជា។ ទិន្នន័យនៃផលទឹកសាបរបស់នាយកដ្ឋានជលផលដែលមានពីមុន គឺមានតែ ៧៥.០០០តោនប៉ុណ្ណោះ តែយោងតាមរបាយណ៍របស់លោក វ៉ាន់ ស្សាលីន ឆ្នាំ១៩៩៨ ការប៉ាន់ស្មានផលចាប់ត្រីទឹកសាបប្រចាំឆ្នាំដែលជាទិន្នន័យថ្មី និងគួរឱ្យជឿជាងនេះទៅទៀត គឺមានពី ២៩០.០០០-៤៥០.០០០តោន ។ យោងតាមទិន្នន័យថ្មីនេះ ប្រទេសកម្ពុជា ជាប្រទេសទីបួនដែលសំបូរត្រីទឹកសាបនៅលើពិភពលោក (តាមរបាយការណ៍របស់លោក ឌីហ្គែន និងសហការី ឆ្នាំ ២០០០)។ ផលិតផលនេះ បានមកពីធ្វើអាជីវកម្មជាលក្ខណៈឧស្សាហកម្ម (ឡូតិ៍នេសាទ[1] និងដាយ[2]) សិប្បកម្ម[3] នេសាទគ្រួសារ[4] និងក្នុងស្រែ[5] (សូមមើលតារាងឧបសម្ព័ន្ធទី១)។

ជាទូទៅ ការគ្រប់គ្រងធនធានត្រីទឹកសាបនៅប្រទេសកម្ពុជា ទទួលឥទ្ធិពលពីនយោបាយ និងរបបសង្គមនិមួយៗនាពេលអតីត និងបច្ចុប្បន្ន។ ប្រពន្ធ័នៃការគ្រប់គ្រងនិមួយៗ ផ្តល់នូវលទ្ធផលទាំងវិជ្ជមាន និងអវិជ្ជមានទៅលើការចិញ្ចឹមជីវិតរបស់ប្រជានេសាទ និងស្ថានភាពធនធានជលផល។ ចាប់តាំងពីរបបប៉ុលពតត្រូវបានបញ្ចប់ (១៩៧៥-១៩៧៩) រហូតមកដល់ពេលបច្ចុប្បន្ននេះ ធនធានជលផលត្រូវបានគ្រប់គ្រង និងធ្វើអាជីវកម្មតាមរបៀបផ្សេងៗគ្នា ដែលអាចសង្ខេបបានដូចមានខាងក្រោម៖

---

១- ឡូតិ៍នេសាទត្រូវបានដាក់ឱ្យដេញថ្លៃ ដោយរាជរដ្ឋាភិបាលកម្ពុជា ផ្តល់នូវសិទ្ធិផ្តាច់មុខលើការធ្វើអាជីវកម្មទាំងស្រុងដែលមានរយៈពេលពីពីរឆ្នាំម្តង ។ នេះជាវិធានការដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើតប្រាក់ចំណូលពីការជួលធនធានជលផល (តាមរបាយការណ៍របស់លោក វ៉ាន់ ស្សាលីន និង សហការី ឆ្នាំ២០០០) ។

២- ដាយជាប្រភេទមងរុំ ឬ ថែវ ដែលដាក់នៅមួយកន្លែងក្នុងទឹក ដើម្បីចាប់ត្រីដែលធ្វើចរាចរណ៍មកក្រោមខ្សែទឹក (តាមរបាយការណ៍របស់លោក វ៉ាន់ ស្សាលីន និង សហការី ឆ្នាំ ២០០០) ។

៣- នេសាទជាលក្ខណៈសិប្បកម្ម ។ នៅប្រទេសកម្ពុជា នេសាទសិប្បកម្មដែលប្រើប្រាស់ឧបករណ៍ធំៗត្រូវតែមានលិខិតអនុញ្ញាតជាមុន ។ វាត្រូវបានអនុញ្ញាតឱ្យប្រើទៅតាមប្រភេទនិងទំហំរបស់ឧបករណ៍នេសាទដែល ធំជាងនេសាទគ្រួសារ (តាមរបាយការណ៍របស់លោក វ៉ាន់ ស្សាលីន និង សហការី ឆ្នាំ២០០០) ។

4&5- នេសាទជាលក្ខណៈគ្រួសារនិងនេសាទក្នុងស្រែ បានបើកសិទ្ធិឱ្យនេសាទដោយមិនចាំបាច់មានលិខិតអនុញ្ញាតទេ ។ ប៉ុន្តែឧបករណ៍នេសាទត្រូវបានរៀបចំតាមច្បាប់ឱ្យប្រើទៅតាមទំហំដែលមានការកំណត់ច្បាស់លាស់ ។ ការធ្វើនេសាទតាមឡូតិ៍នេសាទត្រូវបានបិទនៅរដូវបិទនេសាទ (ពីខែមិថុនា ដល់ ខែ កញ្ញា) (តាមរបាយការណ៍របស់លោក វ៉ាន់ ស្សាលីន និង សហការី ឆ្នាំ២០០០) ។

១៩៧៩-៨២: តំបន់នេសាទជាលក្ខណៈសាធារណៈ

១៩៨២-៨៩: ក្រុមសាមគ្គី

១៩៨៩-៩៨: ឡូតិ៍នេសាទលក់ដោយដាក់ឱ្យដេញថ្លៃ

១៩៩៨-២០០០: ឡូតិ៍នេសាទដែលមានការដាក់ជូលបន្ត និងឡូតិ៍ស្រាវជ្រាវ

២០០១: ដំណាក់ការកែទំរង់ប្រពន្ធ័គ្រប់គ្រងវិស័យជលផល

តាមរបាយណ៍របស់លោក ឌីហ្គែន និងលោក ណៅ ធូក ឆ្នាំ២០០០ បានផ្តល់នូវការបកស្រាយលំអិតមួយនៃការប្រើប្រាស់ធនធានជលផល និងស្ថានភាពការចិញ្ចឹមជីវិតរបស់ប្រជានេសាទចាប់តាំងពីរបបខ្មែរក្រហមមកទល់ឆ្នាំ ១៩៩៩-២០០០។ សំរាប់ការបកស្រាយលំអិត ស្តីពីការជះឥទ្ធិពលនៃប្រពន្ធ័គ្រប់គ្រងផ្សេងៗ ទៅលើការចិញ្ចឹមជីវិតរបស់ប្រជានេសាទនៅឡូតិ៍លេខ ៣ ខេត្តសៀមរាប សូមមើលរបាយការណ៍នៃករណីសិក្សាលេខ៤ ស្តីពីការផ្លាស់ប្តូរបទពិសោធន៍ពីត្បាទៅវិញទៅមករបស់កម្មវិធីសហគមន៍ គ្រប់គ្រងធនធានធម្មជាតិ (CBNRM): ជាករណីសិក្សាតត្តាមួយរបស់កម្មវិធីសហគមន៍គ្រប់គ្រងធនធានធម្មជាតិ (CBNRM) ស្តីពីបឹងទន្លេសាប។

នៅក្នុងអត្ថបទនេះ នឹងចាប់ផ្តើមពិភាក្សាដោយសង្ខេបទៅលើបញ្ហាសំខាន់ៗដែលជាមូលហេតុឱ្យមានការកែទំរង់ប្រពន្ធ័គ្រប់គ្រងវិស័យជលផល។ ការវិភាគទៅលើទស្សនៈរបស់ប្រជានេសាទ ស្តីអំពីសហគ្រប់គ្រង គឺជាចំណុចផ្តោតយ៉ាងសំខាន់ នៅក្នុងអត្ថបទនេះ។

## ២.បញ្ហាសំខាន់ៗ ដែលបណ្តាលឱ្យមានការកែទំរង់ការគ្រប់គ្រងជលផលទឹកសាប

ធនធានជលផលត្រូវបានគេធ្វើអាជីវកម្មយ៉ាងច្រើនលើសលប់ក្នុងកំឡុងរយៈពេលពីរបីឆ្នាំមុននេះ ដោយសារតែការលើកទឹកចិត្តការអភិវឌ្ឍន៍សេដ្ឋកិច្ចបែបទីផ្សារសេរី និងការធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពទូទាំងប្រទេស។ ដោយសារតែឧស្សាហកម្មព្រៃឈើដែលបានផ្តល់កំរៃច្រើនត្រូវបានបញ្ឈប់ ធ្វើឱ្យគេបង្វែរទិសដៅមកវិនិយោគទុនផ្នែកឧស្សាហកម្មជលផលវិញ។

ម្ចាស់ឡូតិ៍នេសាទបានពង្រីកតំបន់ឡូតិ៍នេសាទ ហើយបានកៀបសង្កត់ទៅលើអ្នកនេសាទគ្រួសារតូចតាចកាន់តែច្រើនឡើងក្នុងតំបន់។ ជាងនេះទៀត មានការជ្រៀតជ្រែកពីអ្នកមានអំណាចទាំងនេះ ក្នុងការត្រួតត្រាដែននេសាទផងដែរ។

របាយការណ៍របស់លោកហ្គាម ឆ្នាំ២០០០ បានកត់ត្រាទុកនូវពត៌មានដែលគួរឱ្យជឿបានពីអ្នកនិពន្ធជាច្រើន ស្តីពីបណ្តាបញ្ហានានាទៅក្នុងកំឡុងពេលឆ្នាំ ១៩៩៨-២០០០។ ក្នុងនោះ បញ្ហាសំខាន់ៗ រួមមាន:

-ការផ្តោតលើការប្រមូលប្រាក់ចំណូលពីការធ្វើឡូតិ៍នេសាទ ជាជាងការគ្រប់គ្រងធនធានជលផលដោយមាន និរន្តភាព រឺក៏អភិវឌ្ឍន៍ជនបទដែលមានសមធម៌។

- ទំនាស់រវាងការរានដីព្រៃលិចទឹកធ្វើកសិកម្ម និងការធ្វើអភិរក្ស ។

-ការកើនឡើងនូវអ្នកស្វែងរកផលប្រយោជន៍ពីការធ្វើនេសាទក្នុងរយៈពេលខ្លី (ដូចជា ប្រជាជនក្នុងស្រុក និងក្រៅស្រុក អ្នកនេសាទ ទាហាន និងប៉ូលីស)។

- ភាពតានតឹង និងទំនាស់រវាងអ្នកស្រុក និងម្ចាស់ឡូតិ៍ ក្នុងការប្រើប្រាស់ធនធានធម្មជាតិ។

បញ្ហាដាក់ដូលបន្តនូវតំបន់ឡូតិ៍នេសាទទាំងអស់ឱ្យឯកជន សំរាប់ការធ្វើអាជីវកម្មទាំងស្រុង។

បញ្ហាទាំងនេះ វាធ្វើឱ្យមានការលំបាកទៅលើការប្រើប្រាស់ធនធានជលផល ក្នុងចំណោមអ្នកដែលជាប់ពាក់ព័ន្ធផ្សេងៗ។ ម្ចាស់ឡូតិ៍នេសាទជួលទាហ៊ាន រឺអ្នកយាមប្រដាប់អាវុធ ដើម្បីគំរាមកំហែង បំភ័យ ផាកពិន័យ និងឃុំឃាំងអ្នកស្រុកដែលចូលនេសាទក្នុងតំបន់ឡូតិ៍នេសាទរបស់ពួកគេ។ នៅខេត្តខ្លះ អ្នកនេសាទត្រូវបង់លុយឱ្យម្ចាស់ឡូតិ៍ ដើម្បីបានធ្វើនេសាទនៅក្នុងតំបន់ឡូតិ៍ទាំងនេះ។

ជាឧទាហរណ៍នៅភូមិពាមតាអូរដែលស្ថិតនៅក្នុងតំបន់ឡូតិ៍លេខ ៣ ខេត្តសៀមរាប ប្រជានេសាទត្រូវបង់លុយពី ៦០០ ទៅ ៩០០ ដុល្លា សំរាប់ការនេសាទដោយប្រើឧបករណ៍លបណាំរ៉ាវ និង១៧ ទៅ ៩០ ដុល្លា សំរាប់ឧបករណ៍នេសាទគ្រួសារដូចជាមង សន្ទូចរនង និងព្រាង (សំដីរបស់លោកសន ប៊ុនណា អាយុ ៣២ ឆ្នាំ ជាអ្នកនេសាទ បានប្រាប់អ្នកនិពន្ធតាមការទាក់ទងផ្ទាល់ខ្លួន នៅឆ្នាំ ២០០១)។

ក្រៅពីតំបន់ឡូតិ៍នេសាទ មានទាហាន ប៉ូលីស និងអាជ្ញាធរដែនដី បានរំលោភយកតំបន់នេសាទសាធារណៈទាំងនោះ ហើយបង្ខំឱ្យអ្នកស្រុកបង់លុយសំរាប់ថ្លៃធ្វើនេសាទក្នុងតំបន់ទាំងនេះឱ្យពួកគេ។ ការសង្កត់សង្កិនយ៉ាងខ្លាំងក្លាទាំងនេះ បានបង្កើតឱ្យមានទំនាស់ជាច្រើនរវាងម្ចាស់ឡូតិ៍ និងប្រជានេសាទក្នុងស្រុកក្នុងកំឡុងឆ្នាំ ១៩៩៨-២០០០។ តាមរបាយការណ៍របស់លោកឌីហ្គេន (ឆ្នាំ២០០០) បានកត់ត្រាថា ក្នុងចំណោមប្រាំខេត្តដែលបានជ្រើសរើសយកមកសិក្សា ការប្ដឹងផ្ដល់តវ៉ាមានការកើនឡើង ២០០ ពីឆ្នាំ ១៩៩៨ ដល់ ១៩៩៩ (ក្នុងឆ្នាំ១៩៩៨ មាន ១៦៨ បណ្ដឹង និងឆ្នាំ១៩៩៩ មាន ៣៥៦ បណ្ដឹង)។ ការពិតចំនួនបណ្ដឹងទាំងនេះ អាចច្រើនជាងនេះ ប្រសិនបើគ្មាន ការរារាំង និងទប់ស្កាត់ពីអាជ្ញាធរដែនដីទេនោះ។

ដូចគ្នាដែរ ប្រជានេសាទនៅខេត្តកំពង់ឆ្នាំង និងកំពង់ធំ បានមកតវ៉ានៅខាងមុខសភាជាតិ អស់រយៈពេលពីរបីសប្ដាហ៍នៅក្នុងខែធ្នូកន្លងទៅនេះ។ នៅខែមករា និងកុម្ភៈ ឆ្នាំ ២០០០ ពួកគេបានមកតវ៉ាពីការបាត់បង់សិទ្ធិចូលនេសាទនៅតាមតំបន់នេសាទសាធារណៈដែលពួកគេធ្លាប់មានពីមុនមក[7]។

ដោយបានពិចារណាបញ្ហាដែលជះឥទ្ធិពលដល់ការចិញ្ចឹមជីវិតរបស់ប្រជាជនក្រីក្រ រាជរដ្ឋាភិបាលបានធ្វើការកែទំរង់លើការគ្រប់គ្រងវិស័យជលផលជាបន្ទាន់។ ការកែទំរង់នេះបានតំរូវឱ្យមានការផ្លាស់ប្ដូរប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ខ្ពស់របស់នាយកដ្ឋានជលផល ហើយព្រមទាំងមានការដកចេញ និងបញ្ឈប់ដំណើរការត្រួតពិនិត្យរបស់បណ្ដាស្នាក់ការជលផលខេត្ត ដែលស្ថិតនៅក្នុងតំបន់ឡូតិ៍នេសាទជាច្រើនទូទាំងប្រទេស។ លើសពីនេះ សំណើសុំរបស់អ្នកនេសាទក្នុងការទាមទារយកតំបន់នេសាទសាធារណៈរបស់ពួកគេមកនេសាទវិញបានទទួលផលសំរេច ដោយផ្នែកខ្លះនៃតំបន់ឡូតិ៍នេសាទ រឺឡូតិ៍ទាំងមូលត្រូវបានប្រគល់ឱ្យសហគមន៍ក្នុងតំបន់អ្នកគ្រប់គ្រងវិញ។ ចំនួនឡូតិ៍នេសាទ ដែលបានប្រគល់ឱ្យថ្មីៗដល់សហគមន៍ក្នុងតំបន់មានបង្ហាញនៅតារាងឧបសម្ព័ន្ធទី ៣។

ប្រតិកម្មនៃការកែទំរង់នេះឡើង គឺដោយសារការព្រួយបារម្ភពីការចិញ្ចឹមជីវិតរបស់ប្រជាជន ព្រមជាមួយនេះដែរ ក៏អាចមានពាក្យនិយាយប្រឆាំងដែរថា រាជរដ្ឋាភិបាលធ្វើការកែទំរង់នេះ គឺដើម្បីទាក់ទាញសន្លឹកឆ្នោតសំរាប់ការបោះឆ្នោតថ្នាក់ឃុំដែល

---

7. *កាសែតកោះសន្តិភាព ចេញថ្ងៃទី ៨ ខែមករា ឆ្នាំ ២០០០ កាសែតកម្ពុជាប្រចាំថ្ងៃ ចេញថ្ងៃទី ២៧ មករា ឆ្នាំ ២០០០ និង ចេញថ្ងៃទី ៣ ខែមិនា ឆ្នាំ ២០០០ ។*

និងប្រព្រឹត្តទៅនៅខែកុម្ភៈ ឆ្នាំ២០០២ នាពេលឆាប់ៗខាងមុខនេះ និងក៏ដូចជាសំរាប់ការបោះឆ្នោតថ្នាក់ជាតិ នៅឆ្នាំ ២០០៣ ដែរ ។

**៣.ទស្សនៈរបស់ប្រជានេសាទចំពោះការកែទំរង់ការគ្រប់គ្រងវិស័យជលផល និងសហគ្រប់គ្រងនៃវិស័យជលផល**

លទ្ធផលនៃការចូលរួមវាយតំលៃជនបទមួយ ជាមួយអ្នកនេសាទមួយចំនួននៅតំបន់ឡូតិ៍នេសាទលេខ ៦ និងលេខ ៣ ខេត្តសៀមរាប បានបង្ហាញថាប្រជាជនក្នុងស្រុកមានសេចក្តីរីករាយជាមួយជ័យជំនះរបស់ពួកគេ។ ឥឡូវនេះ ពួកគេមានសិទ្ធិចូលនេសាទដោយមិនចាំបាច់បង់ប្រាក់ឱ្យម្ចាស់ឡូតិ៍នេសាទ រឺពួកក្រុមដែលមានអំណាចដូចពីមុនឡើយ ។

ប្រកាសរបស់នាយករដ្ឋមន្ត្រីហ៊ុនសែន ឱ្យដកស្លាក់ការត្រួតពិនិត្យជលផលគ្រប់ជាន់ថ្នាក់ទាំងអស់ បានធ្វើឱ្យប្រជានេសាទមានទស្សនៈយល់ថាពួកគេមានសិទ្ធិពេញលេញក្នុងការធ្វើនេសាទ។ ប៉ុន្តែពួកអ្នកនេសាទឱកាសនិយម និងអ្នកមានបែរមកឆ្លៀតយកឱកាសនេះ ធ្វើនេសាទអនាធិបតេយ្យប្រើប្រាស់ឧបករណ៍ខុសច្បាប់ និងប្រើវិធីសាស្ត្រចាប់ត្រីទំនើបដូចជា ការប្រើឧបករណ៍ឆក់ ឈិប ម៉ាញ់ និងលបលណាំ។ មិនតែប៉ុណ្ណោះ ពួកគេបានធ្វើការពង្រីង និងបួមបឹងមួយចំនួននៅតាមតំបន់ជុំវិញបឹងទន្លេសាបថែមទៀតផង។

លើសពីនេះ ព្រៃលិចទឹកត្រូវបានកាប់ស្ទើរតែអស់រលីងនៅតាមតំបន់ជាច្រើន។ កត្តានេះ បានធ្វើឱ្យការចិញ្ចឹមជីវិតរបស់ប្រជានេសាទ ពីអំណោយផលល្អរបស់ធនធានជលផលដែលមានស្រាប់ ហើយព្រមទាំងទទួលសិទ្ធិនេសាទពេញលេញតាមរយៈការកែទំរង់ថ្មី ប្រែជាបាត់បង់ទៅវិញ ហើយវានឹងនាំទៅដល់ការបាត់បង់ផលស្តុកត្រីយ៉ាងឆាប់រហ័ស គឺដោយសារតែសកម្មភាពនេសាទខុសច្បាប់ទាំងអស់នេះ។

ហេតុការណ៍ទាំងអស់នេះ បានផ្តល់នូវការឈឺចាប់ចំពោះប្រជាជនដែលបារម្ភពីការអភិវឌ្ឍន៍ធនធានជលផល ទៅថ្ងៃអនាគតដូចជាការការពារ និងថែរក្សា ការគ្រប់គ្រង និងការប្រើប្រាស់ ។ អ្នកនេសាទវ័យចំណាស់ម្នាក់រស់នៅក្នុងតំបន់ឡូតិ៍នេសាទលេខ ៦ ខេត្តសៀមរាប បានបញ្ជាក់ពីការព្រួយបារម្ភរបស់គាត់លើធនធានជលផលទៅថ្ងៃអនាគតសំរាប់កូនចៅជំនាន់ក្រោយរបស់គាត់ដោយសារតែការបំផ្លិចបំផ្លាញ តាមរយៈការធ្វើនេសាទដោយវិធីសាស្ត្រទំនើបៗ និងនេសាទខុសច្បាប់ដោយអ្នកនេសាទដែលមានទឹកប្រាក់ច្រើន និងអ្នកនេសាទខុសច្បាប់ បាននឹងកំពុងបំផ្លិចបំផ្លាញផលស្តុកត្រី។

ការធ្វើនេសាទហួសហេតុ និងការប្រើប្រាស់វិធីសាស្ត្រនេសាទខុសច្បាប់ នឹងបណ្តាលឱ្យបាត់បង់ត្រីមេពូជ និងបំផ្លាញចង្វាក់ចំណីធម្មជាតិធនធានជលផល។ គេគិតថានៅពីរបីឆ្នាំខាងមុខ បរិមាណផលចាប់នឹងថយចុះយ៉ាងខ្លាំង ដោយសារតែផលស្តុកត្រីនៅបឹងធម្មជាតិមានការថយចុះ។ បញ្ហានេះ ប្រាកដជាកើតមានពិត ដោយយោងតាមការទស្សន៍ទាយរបស់លោក ហាឌីន (Hardin) ពីផលវិបាកនៃការបើកឱ្យនេសាទជាចំហ។ ជាមួយគ្នានេះដែរ លោក បាដែន (Baden) និង នូនាណ (Noonan) (ឆ្នាំ១៩៩៨) បានថ្លែងថាៈ "ការហិនហោចវាកើតឡើងលឿនណាស់ គឺនៅមុនពេលត្រូវបានគេគិតគូរពីការរៀបចំប្តូរទ្រង់ទ្រាយស្ថាប័ន រឺ មុនពេលធ្វើការផ្លាស់ប្តូរតំលៃវប្បធម៌ដែលអាចការពារវាបានឡើងវិញ" ។

យោងតាមសេចក្តីថ្លែងការគោលនយោបាយរបស់រាជរដ្ឋាភិបាល គោលបំណងចំបងនៃការកែទំរង់វិស័យជលផល គឺធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពស្បៀង និងកាត់បន្ថយភាពក្រីក្ររបស់អ្នកនេសាទដែលពឹងផ្អែកលើធនធានជលផល។ ជាដំបូងប្រជាជនបានអបអរសាទរជាមួយគោលបំណងនេះ។ ទោះយ៉ាងនេះក្តី ការធ្វើឱ្យប្រសើរឡើងនៃការចិញ្ចឹមជីវិត និងការកាត់បន្ថយភាពក្រីក្រ

តាមរយៈការកែទំរង់វិស័យជលផលនេះ មិនអាចទទួលបានជោគជ័យជានិច្ចនិរន្តទេ។ ទាំងនេះ បណ្តាលមកពីមូលហេតុមួយចំនួនដូចខាងក្រោម:-

-អ្នកក្រមិនមានដើមទុនជាប្រាក់គ្រប់គ្រាន់ ដើម្បីទិញឧបករណ៍នេសាទទំនើបដែលអាចចាប់ត្រីបានច្រើននោះទេ។

-នៅពេលអ្នកក្រធ្វើនេសាទដោយប្រើឧបករណ៍នេសាទដូចជា មង សន្ទូចរនងជាដើម ឧបករណ៍ទាំងនោះត្រូវបានកំទេចដោយឧបករណ៍អូនអូសរបស់អ្នកមានទៅវិញ។

-អ្នកមានកំពុងតែឆ្លៀតយកឱកាស ដើម្បីពង្រឹងការធ្វើអាជីវកម្មរបស់ពួកគេ ដោយទិញឧបករណ៍ទំនើបៗ និងបង្កើនការខំប្រឹងប្រែងក្នុងការធ្វើនេសាទ ដើម្បីចាប់ត្រីឱ្យបានច្រើន និង រកប្រាក់ចំណូលឱ្យបានច្រើនជាងមុន។

ដូច្នេះហើយ បានជាគំលាតរវាងអ្នកមាន និងអ្នកក្រ កាន់តែកើនទ្វេរឡើងថែមទៀត។

## ៤.សហគ្រប់គ្រងនៃធនធានជលផល

ដោយបានឃើញបញ្ហាទាំងនេះ សំនួរមួយបានចោទសួរថា តើសហគមន៍តាមតំបន់អាចគ្រប់គ្រង អាចធ្វើអាជីវកម្ម និងថែរក្សាការពារធនធានជលផល ឱ្យមាននិរន្តភាពដោយរបៀបណា?។ គោលគំនិតនៃសហគ្រប់គ្រងសហគមន៍នេសាទ បានគេដាក់ឱ្យប្រើប្រាស់ ដែលជាមធ្យោបាយមួយដើម្បីសំរេចឱ្យបាននូវគោលបំណងទាំងនេះ។ ថ្វីត្បិតតែ សហគ្រប់គ្រងសហគមន៍នេសាទមួយចំនួនត្រូវបានគេដាក់ឱ្យប្រើប្រាស់ និងអនុវត្តក្នុងតំបន់សហគមន៍ផ្សេងៗគ្នា OCAA នៅទន្លេមេគង្គលើ FAO នៅបឹងទន្លេសាបខេត្តសៀមរាប និងអង្គការអន្តរជាតិជីវិតសេរីមានសហការជាមួយក្រសួងបរិស្ថាននៅឧទ្យានជាតិវីរជ័យ ក៏ដោយ ក៏ពត៌មានអំពីសហគ្រប់គ្រងសហគមន៍នេសាទនៅមិនទាន់បានផ្សព្វផ្សាយឱ្យបានទូលាយដល់អ្នកពាក់ព័ន្ធគ្រប់ជាន់ថ្នាក់នៅឡើយ។ លទ្ធផលមិនត្រឹមតែអ្នកនេសាទសាមញ្ញប៉ុណ្ណោះទេ សូម្បីតែស្ថាប័នបច្ចេកទេសយល់មិនច្បាស់ ថាតើសហគមន៍នេសាទមានន័យ ពិតប្រាកដដូចម្តេច? ហើយត្រូវអនុវត្តយ៉ាង ដូចម្តេចដែរ ?

ការអង្កេតដំបូង គឺដើម្បីស្វែងយល់ពីទស្សនៈ រឺការយល់ដឹងរបស់អ្នកនេសាទក្នុងតំបន់ស្តីអំពីសហគមន៍នេសាទដូចមានបង្ហាញខាងក្រោម :-

-ការភ័ន្តច្រឡំរវាងក្រុមសាមគ្គី រឺការប្រមូលផ្តុំជាក្រុមសហករ និងសហគ្រប់គ្រងសហគមន៍នេសាទ។

-ការផ្តល់ពត៌មានមិនច្បាស់លាស់ ទៅលើអ្វីដែលហៅថាសហគ្រប់គ្រង តាមរយៈមន្ត្រីផ្សព្វផ្សាយ។

-ការយល់ដឹងរបស់សហគមន៍ក្នុងតំបន់នៅមានកំរិតទាប។

-ច្បាប់ជលផលចាស់ហួសសម័យ រឺមិនទាន់សភាពការណ៍។

-ការជំពាក់ទាក់ទិននឹងការផ្លាស់ប្តូរសង្គម

មុនពេលពិភាក្សាបញ្ហានីមួយៗ ជាសំខាន់គឺត្រូវកំណត់ឱ្យបានច្បាស់លាស់នូវពាក្យសហគមន៍នេសាទដែលត្រូវប្រើ ដែលបានបង្កើតឡើងដោយនាយកដ្ឋានជលផល ការិយាល័យជលផលខេត្ត អង្គការ FAO និងLeucena នៅខេត្តសៀមរាប និងបាត់ដំបងជាមុនសិន។ ក្នុងដំណើរបេសកម្ម និងពិគ្រោះយោបល់ជាមួយបុគ្គលិក FAO និងLeucena ពាក្យថាសហគមន៍នេសាទ រឺការគ្រប់គ្រងធនធានជលផលដោយពឹងផ្អែកលើសហគមន៍ ត្រូវបានប្រើប្រាស់ ជាសាមញ្ញជាមួយសហគមន៍ក្នុងតំបន់។

ដូចគ្នានេះដែរ របាយការណ៍របស់កល្យាណ និងសហការី ឆ្នាំ២០០១ បានកត់ត្រាពត៌មានស្តីពីប្រពន្ធ័ អេកូឡូស៊ីបីផ្សេងគ្នាពីក្រុមពិភាក្សាមួយចំនួនដែលក្នុងនោះរួមមានៈការធ្វើកសិកម្មពនេចរនៅតាមតំបន់ដីខ្ពង់រាប តំបន់វាលទំនាបតាមបឹងទន្លេសាប និងតំបន់ឆ្នេរសមុទ្រ។ នៅក្នុងតំបន់ទាំងអស់នេះ ពាក្យសហគមន៍នេសាទ សហគមន៍ព្រៃឈើ និងការចូលរួមគ្រប់គ្រងនៃតំបន់ការពារត្រូវបានគេប្រើប្រាស់ ដើម្បីពណ៌នានូវទំរង់ផ្សេងៗនៃកិច្ចការសហគ្រប់គ្រងដែលត្រូវបាន និងកំពុងអនុវត្តឡើង។

ការបកប្រែជាភាសាខ្មែរនូវពាក្យ សហគមន៍នេសាទនេះ អាចធ្វើអោយមានការភ័ន្តច្រឡំដល់អ្នកអានមួយចំនួនដោយសារតែការពិពណ៌នាពីស្ថានភាពមួយដែលមានន័យថា មានតែសហគមន៍ក្នុងតំបន់មួយគត់ជាម្ចាស់ និងគ្រប់គ្រងធនធានជលផលក្នុងតំបន់មួយនោះបាន។ ការពិតគឺមានន័យថា សហគមន៍នោះ ត្រូវបានចាត់ទុកជាអ្នកពាក់ព័ន្ធមួយដ៏សំខាន់ដែរ ចូលរួមគ្រប់គ្រងជាមួយនឹងអ្នកជាប់ពាក់ព័ន្ធដ៏ទៃទៀត។ ដូចគ្នាដែរ រដ្ឋាភិបាលក៏មានការទទួលខុសត្រូវក្នុងការប្រើប្រាស់ និងគ្រប់គ្រងធនធានជលផលអោយមាននិរន្តរភាព។

ការបកប្រែជាភាសាខ្មែរថា "សហគ្រប់គ្រងនេសាទដែលមានការចូលរួមពីសហគមន៍" រឺ សហគ្រប់គ្រងសហគមន៍នេសាទ" នេះបានប្រាប់អ្នកអានឡាស់លាស់ថា វាជាបែបបទមួយនៃការចែករំលែកអំណាចចូលរួមគ្រប់គ្រងជាមួយបណ្តាអ្នកពាក់ព័ន្ធផ្សេងៗគ្នា។ ហេតុនេះ ពាក្យ "សហគ្រប់គ្រងសហគមន៍នេសាទ" គួរតែត្រូវបានប្រើ ដើម្បីជៀសវាងពីការភ័ន្តច្រឡំ នៅពេលក្រោយទៀត។




លំដាប់ថ្នាក់ (វិវិសាលគម) នៃការរៀបចំសហគ្រប់គ្រង

(កែសំរួលពី **Nielsen** និង សហការី ឆ្នាំ 1997)

ជាឧទាហរណ៍ រចនាសម្ព័ន្ធ និងបណ្តាច្បាប់សហគមន៍នេសាទ គឺមិនត្រូវបង្កើតឡើងទាំងស្រុងដោយគណៈកម្មាធិការគ្រប់គ្រងសហគមន៍នេសាទតែម្នាក់ឯងទេ។ វាត្រូវមានការចែករំលែកអំណាចផ្សេងៗរវាងរដ្ឋាភិបាល និងសហគមន៍ផងដែរ។ ការចែករំលែកនេះ ត្រូវឈរលើលក្ខណៈវិនិច្ឆ័យនៃសហគ្រប់គ្រង។ រូបភាពទី១ខាងក្រោមបង្ហាញពីរបៀបផ្សេងៗនៃការគ្រប់គ្រងដោយរដ្ឋ សហគ្រប់គ្រង និងការគ្រប់គ្រងជាសហគមន៍។ លោក ប៉ូមើរ៉យ (Pomeroy) និង វិលាម (Williams) ក្នុងឆ្នាំ១៩៩៤ បានខំព្យាយាមធ្វើការប្រៀបធៀប និងបង្ហាញភាពខុសគ្នា រវាងសហគ្រប់គ្រងនិងការគ្រប់គ្រងធនធានដោយផ្អែកលើសហគមន៍ (CBRM) (សូមមើលក្នុងតារាងទី ១ ខាងក្រោម)។

★ **ភាពស្រដៀងគ្នារវាងកិច្ចសហគ្រប់គ្រងនិងការគ្រប់គ្រងធនធានផ្អែកលើសហគមន៍**

- រដ្ឋាភិបាលផ្តល់ច្បាប់ និងការទទួលខុសត្រូវអោយសហគមន៍ (CBRM) តាមរយៈសហគ្រប់គ្រង។
- រដ្ឋាភិបាលត្រូវតែបង្កើតសិទ្ធិស្មើគ្នា និងលក្ខខ័ណ្ឌ ដើម្បីបង្កើតអំណាចផ្ទាល់ខ្លួនខ្លះៗ សំរាប់កិច្ចសហការគ្រប់គ្រងផង និងសំរាប់ការគ្រប់គ្រងធនធានផ្អែកលើសហគមន៍ផង ដែលជាយុទ្ធសាស្ត្រគ្រប់គ្រងធនធានអោយមានប្រសិទ្ធិភាព។
- មានតែរដ្ឋាភិបាលប៉ុណ្ណោះ ដែលអាចបង្កើត និងការពារសិទ្ធិនៃអ្នកប្រើប្រាស់បាន និងធានាកម្មសិទ្ធិនៅថ្នាក់សហគមន៍បាន។

**តារាងទី១: ភាពខុសគ្នារវាងសហគ្រប់គ្រង និងការគ្រប់គ្រងធនធានផ្អែកលើសហគមន៍**

| សហគ្រប់គ្រង | ការគ្រប់គ្រងធនធានផ្អែកលើសហគមន៍ |
|---|---|
| សហគ្រប់គ្រងមិនត្រឹមតែបានផ្តោតទៅលើប្រជាជនជាសំខាន់ និងសហគមន៍ប៉ុណ្ណោះទេ ថែមទាំងផ្តោតទៅលើការរៀបចំជាភាគីមួយដែលមានរដ្ឋាភិបាល និង ក្រុមអ្នកប្រើប្រាស់ធនធានក្នុងតំបន់ផងដែរ។<br>• មធ្យោបាយនៃដំណើរការគ្រប់គ្រងធនធានដែល ត្រូវបានបង្កើតឡើង គឺមានទំហំនិងវិសាលធំជាងការគ្រប់គ្រងធនធានផ្អែកលើសហគមន៍។<br>• រដ្ឋាភិបាលមានតួនាទីយ៉ាងសកម្ម និងសំខាន់។ រដ្ឋាភិបាលមានមុខងារសំខាន់ជាច្រើនរួមមាន:<br>• ការផ្តល់នូវការគាំទ្រគោលនយោបាយ និងច្បាប់ដូចជា អំណាចនៃការគ្រប់គ្រង ជាលក្ខណៈវិមជ្ឈការ និងអាជ្ញាធរមូលដ្ឋានក្នុងការជំរុញឱ្យមានការចូលរួមនិងកិច្ចពិភាក្សា ការពង្រឹងច្បាប់នៃសិទ្ធិសហគមន៍ ការផ្តល់គំនិតផ្តួចផ្តើម និងការធ្វើអន្តរាគមន៍ ការប្រតិបត្តិ ការដោះស្រាយបញ្ហាដែលលើសពីលទ្ធភាពរបស់សហគមន៍ ការសំរបសំរួលនៅគ្រប់លំដាប់ថ្នាក់ និងជួយផ្គត់ផ្គង់ផ្នែកបច្ចេកទេស និងថវិកាក្នុងចំណោមបណ្តាស្ថាប័ននានា។ | • គឺផ្តោតទៅលើសហគមន៍និងយកប្រជាជនជាសំខាន់ ។<br>• រដ្ឋាភិបាលជារឿយៗ ដើរតួនាទីបន្ទាប់បន្សំមួយនៅក្នុងសហគមន៍គ្រប់គ្រងធនធាន (CBRM)។ |

## ៥.ការគ្រប់គ្រងរបស់ក្រុមសាមគ្គីនេសាទ ក្រុមសហករ និងសហគ្រប់គ្រងសហគមន៍នេសាទ

ក្នុងការប្រមើមើលជាលើកដំបូង សហគមន៍ និងក្រុមសាមគ្គី គឺមានលក្ខណៈប្រហាក់ប្រហែលគ្នានូវទំរង់រចនាសម្ព័ន្ធនៃគណៈកម្មាធិការ លក្ខណៈការចូលរួមដោយស្ម័គ្រចិត្ត និងការគ្រប់គ្រង និងគោលបំណងមួយចំនួន ។ ប៉ុន្តែ បន្ទាប់ពីមានការពិចារណាហ្មត់ចត់មក វាមានភាពខុសគ្នាមួយចំនួនរវាងក្រុមសាមគ្គី និងសហគមន៍នេសាទ ។ បណ្តាចំណុចទាំងនោះរួមមានៈ-

- ជាទូទៅ ក្រុមសាមគ្គីមានចំនួនសមាជិកតិចជាងសហគមន៍នេសាទ ។
- ក្រុមសាមគ្គីត្រូវបានគេអនុវត្ត នៅក្នុងបណ្តាតំបន់ជាច្រើន ហើយត្រូវបានផ្តោតទៅលើតែសហគមន៍នេសាទ ។
- ក្រុមសាមគ្គីបាននេសាទត្រីក្នុងទំរង់ជាលក្ខណៈរបៀបពាណិជ្ជកម្ម និងចែកផលប្រយោជន៍ស្មើគ្នា ។ ឯនៅក្នុងសហគមន៍នេសាទវិញ អ្នកនេសាទនិមួយៗធ្វើនេសាទជាលក្ខណៈបុគ្គលដោយគោរពទៅតាមច្បាប់នេសាទនិងលក្ខន្តិកៈសហគមន៍ ។
- គោលបំណងចំបងធំមួយក្នុងចំណោមគោលបំណងសំខាន់ផ្សេងៗទៀតរបស់ក្រុមសាមគ្គី គឺការការពារបណ្តាតំបន់ក្នុងភូមិពីការឈ្លានពានពីកំលាំងខ្មែរក្រហម ។ ឯគោលបំណងចំបងធំមួយក្នុងចំណោមគោលបំណងសំខាន់ៗជាច្រើនរបស់សហគមន៍នេសាទនោះ គឺផ្តល់អំណាចអោយប្រជាជនក្នុងតំបន់ ដើម្បីចូលរួមធ្វើផែនការគ្រប់គ្រង ការពារថែរក្សា និងការប្រើប្រាស់ធនធានជលផលអោយមាននិរន្តរភាព ។
- សមាជិកគណៈកម្មាធិការនៃក្រុមសាមគ្គី ត្រូវបានតែងតាំងដោយនាយកដ្ឋានកសិកម្ម និងការិយាល័យជលផលខេត្ត ឯសមាជិកគណៈកម្មាធិការនៃសហគមន៍នេសាទត្រូវបានជ្រើសរើសដោយការបោះឆ្នោតជាលក្ខណៈប្រជាធិបតេយ្យ ។

ក្រុមសហករបានបង្កើតឡើងក្នុងកំឡុងពេលរបបខ្មែរក្រហម (ឆ្នាំ១៩៧៥-៧៩) ។ ឯក្រុមសាមគ្គីបានបង្កើតឡើង ក្នុងកំឡុងពេលពីឆ្នាំ ១៩៨២-៨៩ ក្រោមរបបសង្គមនិយម ។ ក្រុមសហករមានរចនាសម្ព័ន្ធដូចគ្នាក្នុងការអនុវត្តស្ថាប័នរបស់ខ្លួន ដែលស្រដៀងគ្នាទៅនឹងក្រុមសាមគ្គី និងសហគមន៍នេសាទ ។ ទោះបីជាយ៉ាងណាក្តី ក៏ក្រុមសហករមានលក្ខណៈផ្សេងគ្នាមួយចំនួនដូចខាងក្រោមៈ-

- ធ្វើការរួមគ្នានៅក្នុងទំហំមួយដ៏ធំ បើប្រៀបធៀបទៅនឹងក្រុមសាមគ្គី ។
- ហូបបាយរួមគ្នា ប៉ុន្តែគ្មានការចែករំលែកផលប្រយោជន៍គ្នាទេ ។

  សមាជិកគណៈកម្មាធិការបានតែងតាំងដោយអង្គការ ។

ជាទូទៅអ្នកនេសាទបានយល់ឃើញថាសហគ្រប់គ្រងសហគមន៍នេសាទ មានចំណុចមិនល្អ ដោយផ្តោតទៅលើក្រុមសាមគ្គី ។ អ្វីដែលគេបានចងចាំនោះ គឺថាក្រុមសាមគ្គីមានពី ២០-៣០គ្រួសារស្ម័គ្រចិត្ត (ចំនួនសមាជិកខុសគ្នាអាស្រ័យទៅតាមតំបន់នេសាទ ប្រភេទនៃក្រុមសាមគ្គី និងផ្សេងៗទៀត) បានធ្វើការនេសាទត្រីរួមគ្នាជាលក្ខណៈពាណិជ្ជកម្ម ដោយប្រើប្រាស់ឧបករណ៍សាមញ្ញនិងមិនបំផ្លាញផលត្រី ។ រដ្ឋបានផ្តល់លុយទិញឧបករណ៍ និងសំភារៈផ្សេងៗទៀត ។ បន្ទាប់មកពួកគេបានចែកផលត្រី ស្មើគ្នាក្នុងចំណោមសមាជិកពួកគេ ។ ទោះបីជាយ៉ាងណាក្តី ជារឿយៗ វាមានភាពមិនប្រក្រតី និងពុករលួយក្នុងដំណើរការនៃក្រុមសាមគ្គីផងដែរ ។ នេះបានធ្វើអោយគណៈកម្មាធិការនៃក្រុមសាមគ្គីមានទ្រព្យច្រើនជាងសមាជិក ។ មានសមាជិកខ្លះ

បានទទួលផលដោយមិនបានចូលរួមការងារសកម្ម[៥]។ នេះជាផលវិបាកដែលបានបង្កអោយមានលទ្ធផលមិនល្អដល់រដ្ឋ។ ជាងនេះទៅទៀត ការគ្រប់គ្រងខ្សោយ តំលៃប្រេងខ្ពស់ ការឡើងចុះតំលៃលុយរៀល និងការមិនបានឈានចូលដល់ទីផ្សារអន្តរជាតិ។ ការបរាជ័យពីមុនរបស់ក្រុមសាមគ្គី បានធ្វើអោយអ្នកនេសាទក្នុងតំបន់នេះបាក់ទឹកចិត្តពីការចូលរួមក្នុងកិច្ចសហគ្រប់គ្រងសហគមន៍នេសាទ នាពេលបច្ចុប្បន្ន។

ក្នុងករណីខ្លះ អ្នកនេសាទដែលជាមានលុយច្រើនបានយកឱកាសនោះ ថ្លែងបំភ្លើសថា បើអ្នកចូលរួមក្នុងសហគ្រប់គ្រងអ្នកនឹងទទួលបាននូវលទ្ធផលចុងក្រោយដូចក្រុមសាមគ្គីអញ្ចឹង។ នេះជាករណីមួយដែលជួបប្រទះនៅឡូតិ៍នេសាទលេខ ៣ ក្នុងខេត្តបាត់ដំបង និងឡូតិ៍លេខ ៣ ខេត្តសៀមរាប។ វាជាស្ថានភាពមួយដ៏ពិបាកសំរាប់ នាយកដ្ឋានជលផលការិយាល័យជលផលខេត្ត និងបណ្តាអង្គការក្រៅរដ្ឋាភិបាលដែលជាប់ពាក់ព័ន្ធផ្សេងទៀត ក្នុងការព្យាយាមពន្យល់ពីដំណើរការបង្កើតសហគ្រប់គ្រងវិស័យជលផល។

គេបានសង្កេតឃើញថា ប្រសិនបើមានពេលច្រើនដើម្បីពន្យល់ពីគោលបំណង និងផលប្រយោជន៍នៃសហគ្រប់គ្រងសោទ និងភាពខុសគ្នាពីក្រុមសាមគ្គី ប្រជាជននឹងយល់ច្បាស់ ហើយនឹងចូលរួមនៅក្នុងដំណើរការសហការគ្រប់គ្រងនេះ។

## ៦.ការផ្សព្វផ្សាយព័ត៌មានមិនច្បាស់លាស់នៃសហគ្រប់គ្រង តាមរយៈបណ្តាភ្នាក់ងារផ្សព្វផ្សាយ

បុគ្គលិកនៃការិយាល័យជលផលខេត្ត និងបណ្តាបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល បានផ្សព្វផ្សាយស្ទើរតែគ្រប់ឡូតិ៍ទាំងអស់នៅក្នុងទូទាំងប្រទេសកម្ពុជា ស្តីពីដំណើរការសហគ្រប់គ្រង។ ទោះយ៉ាងណាក៏ដោយ នៅពេលខ្លះការផ្សព្វផ្សាយ ពន្យល់ទាំងនោះវាមិនសូវច្បាស់លាស់ទេ ដោយសារបុគ្គលិកក្នុងតំបន់ទាំងនោះមានការយល់ដឹង ផ្នែកសហគ្រប់គ្រងមិនគ្រប់គ្រាន់ហើយពួកគេខ្លួនឯងផ្ទាល់ទើបបានឆ្លងកាត់វគ្គបណ្តុះបណ្តាល។ ជាងនេះទៅទៀត នៅតាមឡូតិ៍នេសាទមួយចំនួនភ្នាក់ងារផ្សព្វផ្សាយ បានប្រើលក្ខន្តិកៈពីសហគ្រប់គ្រងសហគមន៍នេសាទនៅតំបន់ផ្សេង មកបង្រៀនអ្នកនេសាទនៅតំបន់មួយផ្សេងទៀត។ លក្ខន្តិកៈទាំងនេះអាចនឹងមិនអាចយកមកអនុវត្តបានគ្រប់បណ្តាសហគមន៍ទាំងអស់បានទេ។ សកម្មភាពនេះអាចនឹងកាត់បន្ថយការសហការពីប្រជាជនបាន នៅពេលដែលភ្នាក់ងារនោះ ហៅប្រជាជនមកចូលរួមប្រជុំនៅពេលក្រោយៗទៀត។

## ៧.ការយល់ដឹងរបស់សហគមន៍ក្នុងតំបន់

ដូចគ្នានេះដែរ ការយល់ដឹងរបស់អ្នកនេសាទក្នុងតំបន់ គឺនៅទាបណាស់។ នេះគឺជាករណីមួយនៅឡូតិ៍នេសាទលេខ៦ ខេត្តសៀមរាប។ នៅពេលមានគេសួរថា តើអ្នកយល់ពីកម្មវិធីបណ្តុះបណ្តាលសហគមន៍នេសោទឬទេ? គ្មាននរណាម្នាក់ហ៊ានឆ្លើយនូវសំនួរនេះទេ។ ប្រជាជនក្នុងតំបន់នេះនៅតែមិនច្បាស់ថា តើសហគមន៍នេសាទអាចជួយដោះស្រាយបញ្ហានៃការធ្វើអាជីវកម្មហួសហេតុបានការណា។

[៥] គឺសំដៅលើការប្រណែនចំពោះអ្នកដែលមិនបានចូលរួមធ្វើការយ៉ាងសកម្មក្នុងក្រុម ដោយឱ្យខ្លួន ហើយទាមទារចែកផលស្មើគេទៀត។

នៅពេលខ្លះ ការទំនាក់ទំនងមិនច្បាស់លាស់រវាងការិយាល័យជលផលខេត្ត និងអង្គការក្រៅរដ្ឋាភិបាលជាមួយបណ្ដាអាជ្ញាធរមូលដ្ឋាន អាចបង្កអោយមានការរអាក់រអួលដល់ដំណើរការបង្កើតសហគ្រប់គ្រងដែរ ។ នេះគឺជាករណីធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានមិនច្បាស់មួយ ដែលកើតមាននៅឡូត៍នេសាទលេខ៣ ខេត្តបាត់ដំបង ដែលជាទំនាក់ទំនងដំបូង ដើម្បីបង្កើតសហគ្រប់គ្រងសហគមន៍ ។ ជាលទ្ធផល គឺត្រូវចំណាយពេល ដើម្បីដោះស្រាយនូវការយល់ច្រលំទាំងនោះ ។

បុគ្គលិកជលផលក្នុងតំបន់ខ្លះ បានយល់ឃើញថា សហគ្រប់គ្រងសហគមន៍គ្មានបានផលប្រយោជន៍ទេ ។ ពួកគេជឿថា នៅពេលសហគមន៍នេសាទកើតមានឡើង ពួកគេនឹងគ្មានការងារធ្វើ រឺគ្មានអំណាចក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងធនធានជលផលទៀតទេ ។ ដូចគ្នានេះដែរ អ្នកនេសាទខ្លះបានសួរថា តើបុគ្គលិកជលផលនឹងធ្វើអ្វី នៅពេលដែលសហគ្រប់គ្រងសហគមន៍ត្រូវបានបង្កើតឡើង ។ វាបានបញ្ជាក់ច្បាស់ថា ទាំងបុគ្គលិកជលផល និងអ្នកនេសាទក្នុងតំបន់មិនបានយល់ច្បាស់លាស់នូវដំណើរការនៃសហគ្រប់គ្រងនេះ ។

មានការយល់ច្រឡំផ្សេងទៀតជាច្រើន ។ ប្រជាជនក្នុងតំបន់ខ្លះ បានគិតថាការចូលរួមក្នុងកិច្ចប្រជុំនៃ សហគ្រប់គ្រងនេះ គឺក្លាយជាសមាជិកគណៈបក្សនយោបាយណាមួយ ។ ការយល់បែបនេះ បានធ្វើអោយការចូលរួមមានកំរិតទាបនៅក្នុងដំណើរការនៃការបង្កើតសហគ្រប់គ្រងជាសហគមន៍ ។ ប្រជាជនមួយចំនួនមិនចង់ចូលរួម ដោយហេតុគ្មានអំណោយលើកទឹកចិត្តនៅពេលប្រជុំ ។

ក្នុងតំបន់ខ្លះ បណ្ដាអាជ្ញាធរមូលដ្ឋានទាំងប្រធានឃុំ និងចៅហ្វាយស្រុកបានស្ទាក់ស្ទើរ ក្នុងការគាំទ្រការបង្កើតសហគមន៍ ដោយគិតថា សកម្មភាពនេះអាចនឹងបាត់បង់អំណាច និងផលប្រយោជន៍របស់ពួកគេពីការលក់តំបន់នេសាទអោយទៅក្រុមអ្នកនេសាទឯកជន ។

ជាធម្មតាដំណើរការនៃការបង្កើតសហគ្រប់គ្រងទាមទារនូវកិច្ចសហការជិតស្និទ្ធ និងមានការសំរបសំរួលពីណ្ដាអាជ្ញាធរមូលដ្ឋាន ។ ក្នុងករណីខ្លះ ឋានៈរបស់អាជ្ញាធរមូលដ្ឋានអាចជះឥទ្ធិពលដល់ការចូលរួមរបស់ប្រជាជន ។ ជាឧទាហរណ៍នៅឡូត៍នេសាទលេខ៣ ខេត្តបាត់ដំបង ប្រជាជនមានការគោរពតិចតួចទៅតាមការណែនាំរបស់ប្រធានភូមិ ដោយសារគ្រួសាររបស់គាត់មានឋានៈទាប ។

## ៨.ច្បាប់ជលផលចាស់ដែលហួសសម័យ

ប្រជាជនបានយល់ថា សហគ្រប់គ្រងសហគមន៍នេសាទ នឹងដាក់លក្ខខ័ណ្ឌអោយពួកគេធ្វើការនេសាទ ដោយអោយប្រើតែឧបករណ៍នេសាទលក្ខណៈគ្រួសារប៉ុណ្ណោះ យោងតាមច្បាប់នេសាទចាស់ ។ ហេតុដូច្នោះ បើសិនពួកគេចូលរួមក្នុងសហគ្រប់គ្រងសហគមន៍នេសាទ ពួកគេនឹងត្រូវតែគោរពច្បាប់នោះ ។ ប៉ុន្តែការពិត ប្រភេទឧបករណ៍នេសាទស្ទើរតែទាំងអស់ដែលអ្នកនេសាទបានប្រើប្រាស់អាចចាត់ទុកជាប្រភេទឧបករណ៍នេសាទសិប្បកម្ម ។ ដោយសារតែឧបករណ៍នេសាទទាំងនោះ បានកំណត់ដោយច្បាប់គឺមិនអាចចាប់ត្រីបានដូចដែលធ្លាប់បានប្រើពីមុននោះទេ ។ តាមរបាយការណ៍របស់លោក វ៉ាន់ ស្បាលីន និងសហការី ឆ្នាំ២០០០ បានបញ្ជាក់ថា មានឧបករណ៍នេសាទ ១០ប្រភេទ ដែលត្រូវបានគេប្រើជាធម្មតាជាលក្ខណៈនេសាទសិប្បកម្ម (សូមមើលតារាងទី ២) ។

ហេតុដូច្នេះ ច្បាប់នេសាទដែលប្រើការលើងកើត គួរតែធ្វើការកែប្រែ និងសំរេចបោះឆ្នោតដោយរដ្ឋសភា ហើយគួរតែត្រូវយកមកអនុវត្តជាបន្ទាន់ដោយរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាជាក់ស្តែងដែលកំពុងជួបប្រទះដោយក្រុមអ្នកនេសាទ ។

**តារាង២: ប្រភេទឧបករណ៍នេសាទសំខាន់ៗ១០ប្រភេទដែលអនុញ្ញាតិឱ្យប្រើប្រាស់បានជាលក្ខណៈនេសាទសិប្បកម្មនៅប្រទេសកម្ពុជាពីឆ្នាំ ១៩៩៥-៩៦**

| ប្រភេទឧបករណ៍ | ភាគរយនៃផលចាប់សរុប |
|---|---|
| ១-មង | ៥២ |
| ២-អួនហ៊ុម | ១៦ |
| ៣-លបណក់ | ៦ |
| ៤-ទាម | ៣ |
| ៥-មងហ៊ុម | ៣ |
| ៦-សន្ទូច | ៣ |
| ៧-លប | ៣ |
| ៨-អួន | ២ |
| ៩-សំណាញ់ | ២ |
| ១០.សំរាស់ | ២ |
| សរុប | ៩២ |

*ប្រភព: របាយការណ៍របស់លោក ដៀប ឡឹង និងសហការី ឆ្នាំ ១៩៩៨*

*កំណត់សំគាល់: ជាទូទៅមិនត្រូវបានរាយការណ៍ទេ គឺដោយសារតែវិធីសាស្ត្រនៃការនេសាទ វាខុសច្បាប់ ។*

### ៩.ការជំពាក់ទាក់ទិននៅនឹងចំនួនសម្ពាធនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន

ការឈានទៅដល់អារិយធម៌ និងទំនោរសំភារៈនិយមដូចជា ទូរស្សន៍ វីដេអូ និងផ្សេងៗទៀត បានធ្វើអោយមានការកើនឡើងនៃមហិច្ឆិតារបស់ប្រជាជនដែលចង់មានចង់បាន ។ ពីមុនប្រជាជនមិនចង់មានចង់បានខ្លាំងក្លានូវសំភារៈបែបនេះទេ ។

បច្ចុប្បន្ន អ្នកមានអំណាចជាច្រើន ស្ថិតក្នុងគោលជំហរមួយគឺធ្វើអាជីវកម្មលើធនធានធម្មជាតិ ដោយមិនបានគិតគូរ និងទទួលខុសត្រូវនូវអ្វីដែលពួកគេបានធ្វើឡើយ ។ ជូនកាលពួកគេអោយសំណូកទៅមន្ត្រីរដ្ឋ ដើម្បីធ្វើអាជីវកម្មដោយខុសច្បាប់ ។ ជាមួយការគ្មានតម្លាភាព និងភាពទទួលខុសត្រូវទាំងនេះ បានធ្វើឱ្យប្រជាជនក្នុងតំបន់មិនអាចជឿ និងទុកចិត្តក្នុងការបង្កើតសហគមន៍នេសាទដែលនាំមកនូវផលប្រយោជន៍ស្មើរគ្នាជាមួយអ្នកមានទេ ។

ក្នុងបណ្តាឡូត៍នេសាទជាច្រើនដែលមានអ្នកនេសាទជាអ្នកមានច្រើន ជានិច្ចជាកាល វាមានការពិបាកដើម្បីចាប់ផ្តើមដំណើរការអោយបានល្អ ដោយសារតែក្រុមអ្នកសាទដែលជាអ្នកមានទោះបានប្រឆាំង និងប្រពន្ធ័គ្រប់គ្រងដែលធ្វើឱ្យមានសមធម៌។ ជាឧទាហរណ៍ ឡូត៍នេសាទលេខ៣ ក្នុងខេត្តបាត់ដំបង ក្រុមអ្នកនេសាទដែលជាអ្នកមានបានសំដែងចេញនូវពាក្យសំដីប្រឆាំងនឹងសហគ្រប់គ្រងសហគមន៍នេសាទ។

## ១០.សេចក្តីសន្និដ្ឋាន

ដលផលទឹកសាបនៅកម្ពុជា មានសារៈសំខាន់ណាស់សំរាប់ការចិញ្ចឹមជីវិតរបស់ប្រជាជនកម្ពុជា។ ប្រពន្ធ័គ្រប់គ្រងផលផលពីអតីត ដែលបានផ្តោតទៅលើការធ្វើនេសាទជាលក្ខណៈពាណិជ្ជកម្ម តាមរយៈការលក់ឡូត៍នេសាទ ដោយដាក់ឱ្យដេញថ្លៃ ដែលបង្កើតនូវការជះឥទ្ធិពលជាអវិជ្ជមានដល់គ្រួសារ ដែលពឹងផ្អែកលើធនធានជលផល។

កត្តាដែលជំរុញអោយមានការកែទំរង់ទាន់ពេលលើវិស័យជលផលដោយថ្នាក់លើរបស់រដ្ឋាភិបាលជាមួយនឹងគោលបំណងដើម្បីផ្តល់នូវសិទ្ធិនេសាទ ដែលជាទំលាប់ដល់សហគមន៍នេសាទក្នុងតំបន់។ ប៉ុន្តែសកម្មភាពនេះវាបានបង្កអោយមានការនេសាទអាណាធិបតេយ្យខុសច្បាប់ និងការនេសាទលើសលប់នៅតាមតំបន់ជុំវិញបឹងទន្លេសាប ក្នុងអន្តរៈកាលដែលសហគមន៍នេសាទនៅមិនទាន់បានបង្កើតពេញលេញនៅឡើយនៅក្នុងតំបន់។

ដោយបានដឹងនូវបញ្ហាទាំងអស់នេះ ការយកចិត្តទុកដាក់ត្រូវបានធ្វើឡើងដោយផ្តោតទៅលើសហគមន៍នេសាទ វិសហគ្រប់គ្រង ដែលបានចាត់ទុកជាមធ្យោបាយមួយ ដើម្បីសំរេចបាននូវការប្រើប្រាស់ និងការគ្រប់គ្រងធនធានជលផល អោយមានសមធម៌ និងនិរន្តរភាព។ ទោះបីជាយ៉ាងណាក៏ដោយ គំនិតនៃសហគ្រប់គ្រងនេសាទនេះ គឺជាគំនិតថ្មីមួយសំរាប់ប្រជាជនកម្ពុជា។ ប្រជាជននៅមិនទាន់យល់ច្បាស់ និងជឿថាគោលគំនិតនេះ វាសមស្របទៅនឹងស្ថានភាពរបស់ពួកគេឬអត់។ ` សំរាប់ហេតុផលមួយទៀត ចំពោះការទទួលយកតិចតួចនៃគោលគំនិតនេះ គឺថាដំណើរការផ្សព្វផ្សាយ និងការបណ្តុះបណ្តាល ទាំងក្រុមអ្នកផ្សព្វផ្សាយ និងប្រជាជនក្នុងតំបន់ គឺកំពុងតែចាប់ផ្តើម។ ប្រជាជនមួយចំនួននៅតែយល់ថា សហគ្រប់គ្រងនេសាទ គឺគ្មានប្រយោជន៍សំរាប់មុខរបររបស់ពួកគេទេ ដោយពួកគេជឿថា ពេលសហគ្រប់គ្រងនេសាទត្រូវបង្កើតឡើង ពួកគេនឹងត្រូវតែគោរពច្បាប់ការនេសាទ និងលក្ខន្តិកៈរបស់សហគមន៍។ ប្រជាជនផ្សេងទៀតបានគិតថា លក្ខន្តិកៈនៃសហគ្រប់គ្រងនេសាទនឹងអនុញ្ញាតិអោយពួកគាត់នេសាទជាលក្ខណៈគ្រួសារតែប៉ុណ្ណោះ។

## ១១.អនុសាសន៍

- បើសិនជាយើងចង់ធានាអោយមាននិរន្តរភាពលើធនធានជលផល សំរាប់មនុស្សជំនាន់ក្រោយ គួរតែមានការគិតគូរដល់ដំណើរការនៃការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលលើជំនាញសហគ្រប់គ្រងនេសាទនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុក។ សកម្មភាពនេះ នឹងទាមទារការចូលរួមយ៉ាងសកម្ម និងសំរបសំរួលពីអ្នកជាប់ពាក់ពន្ធ័ទាំងអស់ក្នុងសហគមន៍។

- អនុក្រឹត្យស្តីពីសហគមន៍នេសាទ និងច្បាប់នេសាទថ្មី គួរតែអនុវត្តយ៉ាងម៉ត់ចត់ និងបំពេញទៅនឹងស្ថានភាពបច្ចុប្បន្ន

ដែលកំពុងជួបប្រទះ ដោយបណ្តាសហគមន៍ក្នុងតំបន់។ ជាងនេះទៅទៀត ច្បាប់ទាំងអស់នេះ គួរតែត្រូវផ្សព្វផ្សាយ និងអនុវត្តអោយមានប្រសិទ្ធិភាពយ៉ាងឆាប់រហ័ស ដើម្បីធានា និងបញ្ជាក់នូវសិទ្ធិស្របច្បាប់ ហើយមានការទទួលខុសត្រូវដោយសហគមន៍នេសាទក្នុងតំបន់។

- តម្លាភាព និងភាពទទួលខុសត្រូវគួរតែត្រូវបានអនុវត្ត នៅក្នុងដំណើរការរបស់សហគមន៍នេសាទ រឺសហគ្រប់គ្រងនេសាទ ដើម្បីជាសវាងផលអវិជ្ជមាន នៃការធ្វើសហគមន៍នេសាទ ដូចក្រុមសាមគ្គីដែលបានជួបប្រទះពីមុន។
- បណ្តាធនធានរួមមានធនធានមនុស្ស និងថវិកាគួរបែងចែក និងផ្គត់ផ្គង់ដោយរដ្ឋាភិបាល (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីជួយដល់ដំណើរការនៃការបង្កើតសហគមន៍នេសាទ និងការអនុវត្តន៍។
- ការរៀបចំ និងការវិភាគពីស្ថាប័នដែលជាប់ពាក់ព័ន្ធសំរាប់សហគមន៍នេសាទ គួរតែសិក្សា និងរកឱ្យឃើញ ដើម្បីអនុវត្តន៍ឱ្យស្របទៅនឹងបំលាស់ប្តូរនៃការកែទំរង់វិស័យជលផលបច្ចុប្បន្ន។

## ឯកសារយោង: (Refereneces)


Baden J.A. and Noonan, D.S. (1998). "Managing the Commons". Indiana University Press: Bloomington and Indianapolis;

Degen, P., Van Acker, F., van Zalinge, N., Nao, T., and Deap, L. (2000). "Taken for Granted: Conflicts over Cambodia's Freshwater Fish Resources". Contribution to the 8th IASCP Conference, Bloomington, Indiana, 31 May to 4 June 2000;

Gum, W. (2000). "Inland Aquatic Resources and Livelihoods in Cambodia: A Guide to the Literature, Legislation, Institutional Framework and Recommendations". Oxfam GB and NGO Forum on Cambodia: Phnom Penh;

Hou, K., Srey, M., Thay. S., Prak, M., Chean, T., and Ouk, L. (2001). "Case Study on CBNRM in Cambodia-Lessons Shared". CBNRM/WWF/IDRC/Oxfam:Phnom Penh;

Pomeroy, R.S. and Williams, M.J. (1994). Fisheries Co-management and small-scale fisheries: a policy brief. ICLARM: Manila;

van Zalinge, N., Nao, T., Touch, S.T. and Deap L. (2000). "Where There is Water, There is Fish? Cambodian Fisheries Issues in a Mekong River Basin Perspective" in Common Property in the Mekong: Issues of Sustainability and Subsistence. (2000). ICLARM, Australian Mekong Resource Centre and Sida.

**សហគមន៍នេសាទ**

សហគមន៍នេសាទជាទំរង់មួយថ្មីសំរាប់ការរៀបចំការគ្រប់គ្រងធនធាន ដើម្បីសមស្របតាមគោលនយោបាយរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ ២០០១ ។ គំរោងមួយហៅថា "ការចូលរួមគ្រប់គ្រងធនធានធម្មជាតិនៅក្នុងតំបន់បឹងទន្លេសាប" កំពុងបានធ្វើការអភិវឌ្ឍន៍ និងជំរុញអោយមានការគ្រប់គ្រងធនធានធម្មជាតិ ដោយមានការចូលរួមនៅខេត្តសៀមរាបក្នុង ឆ្នាំ១៩៩៥។ គំរោងនេះ បានរៀបចំរបៀបគ្រប់គ្រងធនធានតាមលក្ខណៈសហគមន៍ ព្រមទាំងបានជួយជំរុញអោយមានដំណើរការកែទំរង់វិស័យជលផលនៅទឹកសាប ដែលទទួលបានលទ្ធផលនូវចំនួនផ្ទៃដី ៥៣៦.០០០ ហិចតា ត្រូវបានកាត់ចេញ ពីឡូត៍ធ្វើអាជីវកម្ម ដើម្បីប្រគល់ជូនសហគមន៍មូល ដ្ឋានសំរាប់ការរៀបចំសហគមន៍នេសាទនៅឆ្នាំ ២០០១។

គំរោង "ការចូលរួមគ្រប់គ្រងធនធានធម្មជាតិនៅក្នុងតំបន់បឹងទន្លេសាប" ត្រូវបានពង្រាងចេញនៅឆ្នាំ ១៩៩៤ ដោយប្រឈមមុខដោះស្រាយការបំផ្លិចបំផ្លាញព្រៃឈើ ព្រមទាំងការរានព្រៃលិចទឹកដើម្បីយកដីធ្វើការដាំដុះដំណាំផ្សេងៗ ពិសេសការគំរាមកំហែងធនធានជលផល។ គំរោងនេះ ត្រូវបានឧបត្ថម្ភដោយរដ្ឋាភិបាន បែលស៊ិក ដោយអនុវត្តឆ្លងកាត់អង្គការ សន្តិសុខស្បៀង ការងារកសិកម្មរបស់អង្គការសហប្រជាជាតិ។ គំរោងនេះ បានរៀបចំជាគំរោងសាកល្បងក្នុងដំណាក់កាលទី១ (១៩៩៥-៩៧) ដែលផ្តោតទៅលើការសិក្សាស្រាវជ្រាវ និងការប្រមូលទិន្នន័យនៅលើសហគមន៍នេសាទ ព្រមទាំងការស្រាវជ្រាវ ពីរុក្ខជាតិ និងសត្វគ្រប់ប្រភេទនៅតំបន់បឹងទន្លេសាបក្នុងខេត្តសៀមរាប (តារាងទី១)។ ដំណាក់កាលទី ២ (១៩៩៨-២០០១) ត្រូវបានពង្រីកលើតំបន់គោលដៅទូទាំងខេត្តសៀមរាប ដោយបានផ្តោតលើការអនុវត្តការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមទាំងផ្នែកព្រៃ និងជលផលនៅមូលដ្ឋាន។ បច្ចុប្បន្ន គំរោងនេះ បានឈានចូលដល់ដំណាក់កាលទី ៣ នៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០១ ដែលផ្តោតលើការធ្វើការងាររួមគ្នា និងវិធីសាស្ត្រគំរូសំរាប់អនុវត្តសហគមន៍នេសាទ និងព្រៃឈើ។ ដូចនេះផងដែរ គំរោងនេះបានសង្កត់ធ្ងន់ទៅលើសត្តភាពបុគ្គលិក និងសហគមន៍មូលដ្ឋាន ព្រមទាំងមន្ត្រីរដ្ឋាភិបាល នៃស្ថាប័ដនាញពាក់ព័ន្ធនៅក្នុងខេត្តសៀមរាបដែលកំពុងធ្វើការងារនៅតំបន់បឹងទន្លេសាប ដើម្បីជំរុញអោយមានបច្ចេកទេសត្រឹមត្រូវ និងប្រសិទ្ធសាស្ត្រល្អ ។

**ដំណើរការរបស់គំរោង**

ដំណើរការរៀបចំសហគមន៍នេសាទត្រូវបានអនុវត្ត នៅក្នុងខេត្តសៀមរាប ហើយបានជួយរៀបចំដោយគំរោងអស់រយៈពេលជាង ៤ឆ្នាំ ដោយនៅពេលដំបូងបានធ្វើនៅតំបនព្រៃឈើខ្ពង់រាប។ បច្ចុប្បន្នគំរោងនេះ ត្រូវបានបត់បែនទៅតាមបញ្ហាជាក់លាក់របស់សហគមន៍នេសាទ ហើយក៏ជាគំរូការចាំបាច់ជាបន្ទាន់ក្នុងការបង្កើតសហគមន៍ ដើម្បីគ្រប់គ្រងលើផ្ទៃឡូត៍នេសាទ ដែលបានកាត់ដោយសហគមន៍មូលដ្ឋាន។ នេះជាការសង្ខេបនូវដំណើរការរៀបចំដូចខាងក្រោម:

១-ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន

លិខិតជាផ្លូវការត្រូវបានផ្តល់ពីអាជ្ញាធរដែនដីជូនទៅកាន់អភិបាលស្រុកដើម្បីអនុញ្ញាតិអោយក្រុមសំរបសំរួលអនុវត្តការងារ។

គោលបំណង និងការងារពាក់ព័ន្ធត្រូវបានបកស្រាយយ៉ាងច្បាស់លាស់

អភិបាលស្រុក និងអាជ្ញាធរពាក់ព័ន្ធ( មេឃុំ ឧតបាល) នៅក្នុងដំណើរការពាក់ព័ន្ធនេះ

២-ក្រុមអ្នកប្រើប្រាស់

- អ្នកប្រើប្រាស់នៅខាងក្នុង និងអ្នកខាងក្រៅ ត្រូវបានគូសបញ្ជាក់ដោយឆ្លងកាត់អាជ្ញាធរមូលដ្ឋាន ប្រធានភូមិប្រជានេសាទក្នុងស្រុក
- កិច្ចពិភាក្សាត្រូវអនុវត្ត ដើម្បីបានទទួលព័ត៌មានត្រឹមត្រូវ

៣-ការចូលរួមធ្វើការប៉ាន់ស្មានលើធនធាន

- ទីតាំងនៃការធ្វើ PRA បានប្រព្រឹត្តទៅជាមួយអ្នកប្រើប្រាស់ខាងក្នុង និងអ្នកខាងក្រៅដែលមានទំនាក់ទំនង និងការប្រើប្រាស់ធនធានដូចជា ការផ្គត់ផ្គង់ តំរូវការ បញ្ហាជំលោះ ។ល។

៤-ការប្រជុំនៅក្នុងភូមិ

- ការប្រជុំត្រូវបានអនុវត្តឡើងនៅក្នុងភូមិនីមួយៗ ដើម្បីពិភាក្សា នូវលទ្ធផលនៃការធ្វើ PRA និងពិនិត្យឡើងវិញនៅលើផែនទីដែលបានគ្រោង
- ការកំណត់នូវតំបន់ដែលប្រើប្រាស់ធនធាននៅក្នុងភូមិនីមួយៗ ដើម្បីធ្វើការរៀបចំគ្រប់គ្រង
- ការជ្រើសរើសអ្នកតំណាងភូមិ ដែលមានកិរិតពីថ្នាក់ភូមិរហូតដល់គណៈកម្មការសហគមន៍នេសាទ
- កំណត់ពីគោលបំណងនៃការរៀបចំធនធាន ដើម្បីធ្វើព្រាងពីបទបញ្ញត្ត និងលក្ខន្តិកៈ

៥-សិក្ខាសាលាថ្នាក់កណ្តាល

- បានប្រារព្ធសិក្ខាសាលាដោយមាការចូលរួមសមាជិកគណៈកម្មការភូមិ ឃុំ និងអាជ្ញាធរដែនដី ដើម្បីជ្រើសរើសគណៈកម្មការគ្រប់គ្រងកណ្តាល ព្រមជាមួយអ្នកតំណាងមកពីភូមិមួយៗ ។
- ការកំណត់អោយច្បាស់លាស់លើព្រំប្រទល់សំរាប់គ្រប់គ្រង ។
- ដាក់ឈ្មោះលើតំបន់ដែលទទួខុសត្រូវ ដើម្បីបង្កើតនូវសកម្មភាពសំរាប់ការពារ និងការងារផ្សព្វផ្សាយ

៦-ការកំណត់ និងការគូលើផែនទី

- ធនធានសហគមន៍នេសាទត្រូវបានកំណត់ដោយមានការគូនៅលើផែនទីតាមឧបករណ៍ GPS
- ការកិរិតលើផែនទីត្រូវបានធ្វើឡើង ។

៧-បទបញ្ញត្តិ និងលក្ខន្តិកៈ

- បទបញ្ញត្តិ និងលក្ខន្តិកៈត្រូវបានធ្វើបញ្ចប់នៅតាមទីតាំងសហគមន៍នីមួយៗ ដោយគណៈកម្មការកណ្តាលរបស់ពួកគេ ព្រមទាំងបានប្រកាសជាសាធារណៈចំពោះផែនទីដែលធ្វើរួចទៅដល់អ្នកពាក់ពន្ធ័ប្រើប្រាស់ទាំងអស់នៅក្នុងតំបន់ ពិសេសអ្នកមានភារកិច្ចគ្រប់គ្រងធនធាននេះ ។
- បទបញ្ញត្តិ និងលក្ខន្តិកៈ ត្រូវបានព្រមព្រៀង និងចុះហត្ថលេខា ដោយគណៈកម្មការកណ្តាល អភិបាលស្រុក ប្រធានមន្ទីកសិកម្ម រុក្ខាប្រមាញ់ និងជលផលខេត្ត និងថ្នាក់ដឹកនាំនៃក្រសួកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៨-ផែនការគ្រប់គ្រង

- ការពិគ្រោះយោបល់រវាងគណៈកម្មការកណ្តាល និងគណៈកម្មការភូមិ ព្រមទាំងប្រជាននេសាទ ដើម្បីធ្វើពង្រាងផែនការសកម្មភាពរយៈពេល ៥ឆ្នាំ ដែលទាក់ទងការការពារធនធានធម្មជាតិ ការគ្រប់គ្រង ព្រមទាំងការទទួលផលប្រយោជន៍ ។

  គោលបំណងនៃការដំណើរការរៀបចំសហគមន៍នេសាទ គឺជួយផ្តល់អំណាចអោយសហគមន៍មូលដ្ឋានសមក្រប់ការការពារ និងការចូលរួមគ្រប់គ្រងធនធាន និងធនធានជលផល ដែលពួកគេកំពុងពឹងផ្អែកលើធនធាននេះទាំងស្រុង។

**សន្និដ្ឋាន**

យុទ្ធសាស្ត្រចំបងនៅក្នុងការគ្រប់គ្រងសហគមន៍នេសាទ គឺត្រូវតែផ្តល់ការទទួលខុសត្រូវលើការការពារ និងការគ្រប់គ្រងធនធាន ពីរដ្ឋាភិបាល ជូនដល់សហគមន៍មូលដ្ឋាន។ ជាក់ស្តែង នៅក្នុងប្រទេសកម្ពុជា ធនធានដែលសហគមន៍មូលដ្ឋានមាន ជាដំបូងគឺ ដី ឧទាហរណ៍ តំបន់ព្រៃលិចទឹករាប់ពាន់ហិចតា ដីព្រៃ ត្រពាំង បឹង អូរ និងព្រែកនៅរដូវប្រាំង។ ថ្មីៗនេះ ផ្ទៃឡូត៍នេសាទត្រូវបានកាត់ចេញជាច្រើនហិចតា ដើម្បីប្រគល់ទៅសហគមន៍មូលដ្ឋាន សំរាប់រៀបចំសហគមន៍ តែបើមាន ការគ្រប់គ្រងត្រឹមត្រូវ សហគមន៍នេសាទនិងធានាបាននូវសន្តិសុខស្បៀង ព្រមទាំងជំរុញអោយផ្នែកសេដ្ឋកិច្ចក្នុងស្រុក។ ច្បាប់ត្រូវបានតាក់តែងឡើងដើម្បីជួយគាំទ្រដល់គោលនយោបាយថ្មី របស់រដ្ឋាភិបាលដែលកំពុងធ្វើការសំរាប់ធានាបាននូវការអនុវត្ត។

គំរោងករណីសិក្សាការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម និងបណ្តាញការងារត្រូវបានសំរបសំរួលដោយស្ថាប័នចំរុះ និងក្រុមស្នូលស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា ព្រមទាំងដៃគូសហការផ្សេងៗដែលមានសមាសភាពចូលរួមពីស្ថាប័នផ្សេងៗដូចជា ស្ថាប័នរដ្ឋាភិបាល ក្រុមអង្គការ ស្ថាប័នបណ្តុះបណ្តាល និងសហគមន៍មូលដ្ឋាន សង្គមស៊ីវិលដែលកំពុងបានអនុវត្តការងារនៅតំបន់ខ្ពង់រាប ទំនាបកណ្តាល តំបន់មេគង្គ ព្រមទាំងតំបន់ឆ្នេរ ។

គំរោងនេះបានគាំទ្រដល់វិធីសាស្ត្រនៃការភ្ជាប់ទំនាក់ទំនងនៅមូលដ្ឋានដែលបានជំរុញ និងលើកទឹកចិត្តអោយសហគមន៍មូលដ្ឋានបានចូលរួមយ៉ាងសកម្មក្នុងការអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពតាមរយៈ :

- សហគមន៍ព្រៃឈើ
- សហគ្រប់គ្រងធនធានជលផល
- ការធ្វើផែនការប្រើប្រាស់ដីដោយមានការចូលរួម និង
- ការចូលរួមគ្រប់គ្រងតំបន់ការពារ ។

ទិសដៅចុងក្រោយរបស់គំរោងនេះ គឺដើម្បីលើកកំពស់ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់រាជរដ្ឋាភិបាលកម្ពុជា ។

គោលបំណងជាក់លាក់របស់គំរោងគឺ :

- ការកសាងសមត្ថភាព
- រៀនសូត្រពីបទពិសោធន៍
- បណ្តាញការងារ
- ការគាំទ្រគោលនយោបាយ

សកម្មភាពបន្តរបស់គំរោងរួមមានការបង្កើតឡើងនូវទស្សនៈទានសំខាន់ៗ និងការវិភាគលើក្រោងការណ៍សំរាប់អនុវត្តលើគំរោង "ការចូលរួមគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម" នៅកម្ពុជា ។ ជាមួយគ្នានេះដែរ ការកសាងសមត្ថភាពតាមរយៈការអនុវត្តការងារក្រោងករណីសិក្សា ដើម្បីបង្កើនការស្រាវជ្រាវ ការរៀបចំឯកសារជំនាញលើការវិភាគ និងការកសាងបណ្តាញការងាររវាងអ្នកគាំទ្រ "ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម" ទូទាំងប្រទេស និងថ្នាក់តំបន់ ព្រមទាំងការគាំទ្រនូវដំណើរការពិគ្រោះយោបល់សំរាប់ការអភិវឌ្ឍន៍គោលការណ៍ច្បាប់ និងបទដ្ឋានច្បាប់នានាដែលមានការពាក់ព័ន្ធ ។

**អង្គការដែលជាដៃគូអនុវត្តការងារជាមួយគំរោងករណីសិក្សា "ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម និងបណ្តាញការងារ"**

- ✓ ការិយាល័យសហគមន៍ធនធានធម្មជាតិ និងតំបន់ទ្រនាប់
- ✓ នាយកដ្ឋានការពារអភិរក្ស ការពារធម្មជាតិ( ក្រសួងបរិស្ថាន)
- ✓ នាយកដ្ឋានរុក្ខា-ប្រមាញ់ និងសត្វព្រៃ ( ក្រសួងកសិកម្ម)
- ✓ នាយកដ្ឋានជលផល( ក្រសួងកសិកម្ម)
- ✓ អង្គការមូលនិធិពិភពលោកសំរាប់ធម្មជាតិ
- ✓ មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍អន្តរជាតិ
- ✓ មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើថ្នាក់តំបន់
- ✓ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
- ✓ អង្គការអុកស្វាមអាមេរិកាំង
- ✓ គំរោងការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាងនៅតំបន់ឆ្នេរ
- ✓ ឧទ្យានជាតិរាម នៃក្រុងព្រះសីហនុ
- ✓ អង្គការខុនសឺន
- ✓ គំរោងការចូលរួមគ្រប់គ្រងធនធានធម្មជាតិនៅតំបន់ទន្លេសាប
- ✓ អង្គការជំនួយសហគមន៍បរទេសនៃអុកស្វាម( ស៊ឹងត្រែង)
- ✓ គំរោងស្តីពី " ការស្រាវជ្រាវសហគមន៍ព្រៃឈើ "
- ✓ គំរោងអនុផលព្រៃឈើ ខេត្តរតនៈគីរី
- ✓ គំរោងភាពជាដៃគូនៃអភិបាលកិច្ចមូលដ្ឋាន
- ✓ MOSAIC ខេត្តមណ្ឌលគីរី
- ✓ GTZ-CGFP
- ✓ សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- ✓ សាកលវិទ្យាល័យភ្នំពេញ ( មហាវិទ្យាល័យវិទ្យាសាស្ត្របរិស្ថាន)
- ✓ ក្រុមការងារសហគមន៍ព្រៃឈើ
- ✓ ក្រុមការងារច្បាប់ជលផល
- ✓ ក្រុមបណ្តុះបណ្តាលផែនការគ្រប់គ្រងដីធ្លីដោយមានការចូលរួម
- ✓ ក្រុមបណ្តាញការងារសហគមន៍ព្រៃឈើ
- ✓ វេទិការបស់អង្គការក្រៅរដ្ឋាភិបាល ស្តីពីបរិស្ថាន

**តារាងឧបសម្ព័ន្ធទី ១ ផលនេសាទចាប់បានប្រចាំឆ្នាំនៅកម្ពុជាពីឆ្នាំ ១៩៩៤ ដល់ ១៩៩៧**

| ប្រភេទនៃការនេសាទ | ផលចាប់ប្រចាំឆ្នាំ |
|---|---|
| នេសាទឧស្សាហកម្ម:- | |
| នេសាទតាមឡូត៍[1] | ២៥ ០០០-៧៥ ០០០ |
| ដាយ[2] | ១៤ ០០០- ១៦ ០០០ |
| នេសាទសិប្បកម្ម[3] | ៨៥ ០០០-១០០ ០០០ |
| នេសាទគ្រួសារ[3] | ១១៥ ០០០-១៤០ ០០០ |
| នេសាទតាមស្រែ[4] | ៥០ ០០០-១០០ ០០០ |
| សរុប | ២៨៩ ០០០-៤៣១ ០០០ |

*ប្រភព: របាយការណ៍របស់លោក អាហ៊ីត និងសហការី ឆ្នាំ ១៩៩៨ និងរបស់លោក ដៀប ឡឿង និងសហការី ឆ្នាំ ១៩៩៨ ។*

*កំណត់សំគាល់*

*១. តម្លៃនៃផលចាប់ជាក់ស្តែង ស្ថិតនៅចន្លោះមិនពិតប្រាកដ ។*

*២. ផលចាប់ បានបង្ហាញពីតំលៃប្រហាក់ប្រហែលដែលនៅចន្លោះរវាងអប្បបរមា និងអតិបរមា ។*

*៣. ដោយផ្អែកលើទិន្នន័យនៃការអង្កេតសេដ្ឋកិច្ចសង្គមដែលបានចាត់ស្មានសរុបទូទាំងប្រទេស ។*

*៤. ប្រមាណប្រហែល ១.៨ លាន ហត X ផលចាប់ក្នុងមួយឆ្នាំ: ២៥-៦២ គក្រ /ហត ។*

## តារាងឧបសម្ព័ន្ធទី ២: ផែនទីបង្ហាញពីទីតាំងសិក្សា នៅឡូត៍លេខ ៣ និង ៦ ខេត្តសៀមរាប និងឡូត៍លេខ ៣ និងឡូត៍លេខ ៥ ខេត្តបាត់ដំបង

Appendix 2: Map showing studied sites at fishing lot #3 and #6 of siem Reap



តារាងឧបសម្ព័ន្ធទី ៣: ផែនទីបង្ហាញពីតំបន់ធ្វើការសិក្សានៅឡូលេខ៥ ខេត្តបាត់ដំបង

Appendix 3: Map showing studied sites at #5 of Battambang Province

**Battambang Fishing Lots**



## តារាងឧបសម្ព័ន្ធទី ៤: តំបន់ឡូតិ៍នេសាទក្រោយពេលកែទំរង់វិស័យជលផល

## Appendix 4: Recent updated fishing lots throughout Cambodia



E20-20



# Fisheries Policy Reforms and the Current Perceptions about Community Fisheries and Co-Management of Fisheries

**A Case Study**

*from selected fishing lot areas
of Siem Reap and Battambang Provinces
Kingdom of Cambodia*

*Written by: Thay Somony*

**2002**

**Fisheries Policy Reforms and the Current Perceptions about Community Fisheries and Co-Management of Fisheries**

## A Case Study

*from selected fishing lot areas of Siem Reap and Battambang Provinces Kingdom of Cambodia*

*Written by: Thay Somony*

**2002**

Freshwater fisheries are of very significant importance to the livelihood of people in Cambodia. The aim of fisheries' reforms is to reduce negative impacts of the previous system, alleviate poverty and to bring customary fishing rights back to poor local fishing communities. The development of community fisheries and co-management of fisheries is regarded as an alternative to achieve sustainable and equitable use and management of fisheries resources. However, this concept is very new to the Cambodian context and there is a general lack of understanding and poor acceptance in some areas. Some people still perceive fisheries co-management as a disadvantage to their occupation as they (correctly) believe that they will now have to abide by the regulation or statutes of the community fisheries. Others have thought that this reform will only allow for small-scale family fishing. These perceptions are important to analyze in order to implement fisheries co-management as a successful strategy of the recent fisheries policy reforms.

